គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# របាយការណ៍សមិទ្ធកម្ម
# ប្រចាំត្រីមាសទី១ ឆ្នាំ២០១៦
# នៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី៣
# របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អគ្គលេខាធិការដ្ឋាន

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ខែមិថុនា ឆ្នាំ២០១៦

# មាតិកានុក្រម

I. សេចក្តីផ្តើម ........................................................................................................ ០១
II. លទ្ធផលសម្រេចបានតាមផ្នែក........................................................................................ ០១
III. បញ្ហាប្រឈម .................................................................................................... ៣០
IV. សំណូមពរ....................................................................................................... ៣០
V. សេចក្តីសន្និដ្ឋាន................................................................................................... ៣១
ឧបសម្ព័ន្ធ៖ តារាងរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០១៦

## I. **សេចក្តីផ្តើម**

របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ នេះ ជារបាយការណ៍ដែលបង្ហាញឱ្យដឹងពីសមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈមនានា ដែលបានកើតឡើងក្នុងការអនុវត្ត **ផែនការសកម្មភាព ដំណាក់កាលទី៣ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផែនការសកម្មភាពដំណាក់កាលទី ០៣ នេះ ត្រូវបានគាំទ្រដោយផ្នែកចំនួន ០៥ គឺ÷

១. ផ្នែកទី១÷ ភាពជឿទុកចិត្តនៃថវិកា

២. ផ្នែកទី២÷ គណនេយ្យភាពហិរញ្ញវត្ថុ

៣. ផ្នែកទី៣÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

៤. ផ្នែកទី៤÷ ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់

៥. ផ្នែកទី៥÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព

ជាមួយគ្នានេះ ការតាមដានត្រួតពិនិត្យដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ) ត្រូវបានធ្វើឡើងប្រកបដោយភាពម៉ត់ចត់ ច្បាស់លាស់ និងទៀងទាត់តាមរយៈកិច្ចប្រជុំប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ សម្រាប់ធ្វើការវាយតម្លៃពីប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។

របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសទី១ នឹងរៀបរាប់ពីលទ្ធផលសម្រេចបាន ដោយលម្អិតទៅតាមផ្នែកនីមួយៗ រហូតដល់កម្រិតគោលបំណង និងចង្កោមសកម្មភាពធៀបនឹងសូចនាករ ព្រមទាំងលើកឡើងពីបញ្ហាប្រឈម សំណូមពរ និងការងារត្រូវធ្វើបន្តផងដែរ។

វិធីសាស្ត្រដែលប្រើប្រាស់សម្រាប់វាយតម្លៃសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាព ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ នេះ ផ្អែកលើមូលដ្ឋាន២ គឺ÷

១. សកម្មភាពការងារសម្រេចបានធៀបនឹងសកម្មភាពដែលបានគ្រោងអនុវត្ត

២. លទ្ធផលសម្រេចបានធៀបនឹងសូចនាករគោលដៅ។

ក្នុងនោះដែរ ការផ្តល់និទ្ទេសវាយតម្លៃលើវឌ្ឍនភាពសម្រេចបាន ត្រូវបានបែងចែកជា ៣ កម្រិត សម្រាប់គោលបំណង និងចង្កោមសកម្មភាពគឺ÷ ល្អ(៩០% - ១០០%), មធ្យម(៨០%- ក្រោម ៩០%), និង ខ្សោយ(ក្រោម ៨០%) ។

## II. **លទ្ធផលសម្រេចបានតាមផ្នែក**

សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៦ នេះ នៅក្នុងផែនការសកម្មភាព ដំណាក់កាលទី ៣ នេះ ដែលគាំទ្រដោយ ០៥ ផ្នែក រួមមានគោលបំណងចំនួន ២១ និងចង្កោមសកម្មភាពចំនួន៦៨។ សកម្មភាពការងារជាច្រើនត្រូវបានកំណត់ និងអនុវត្តដោយអង្គភាពចំនួន១៤ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការចូលរួមពីគ្រប់ក្រសួង-ស្ថាប័ន។ ជារួមឃើញថា ស្ថានភាពនៃផ្នែកទាំង៥ ទទួលបានលទ្ធផលជារួមដូចតទៅ÷ ផ្នែកភាពជឿទុកចិត្តនៃថវិកា មាន ០៤ គោលបំណង និង ១៤ ចង្កោមសកម្មភាព សម្រេចបាន ៨៨%, ផ្នែកបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ មាន ០៤ គោលបំណង និង ១៤ ចង្កោមសកម្មភាព សម្រេចបាន ៦៧%, ផ្នែកការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ មាន ០៦

គោលបំណង និង ២៣ ចង្កោមសកម្មភាព សម្រេចបាន ៨៥%, ផ្នែកការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ មាន ០៤ គោលបំណង និង ០៩ ចង្កោមសកម្មភាព សម្រេចបាន ២០%, និងផ្នែកការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ មាន ០៣ គោលបំណង និង ០៨ ចង្កោមសកម្មភាព សម្រេចបាន ៧១%។

## ១. ភាពជឿទុកចិត្តនៃថវិកា

### ១.១. លទ្ធផលលើសូចនាករសមិទ្ធកម្មគន្លឹះប្រចាំត្រីមាសទី១ ឆ្នាំ២០១៦

| សូចនាករ | គោលដៅ | វឌ្ឍនភាពត្រីមាសទី១ ឆ្នាំ ២០១៥ | វឌ្ឍនភាពត្រីមាសទី១ ឆ្នាំ ២០១៦ |
|---|---|---|---|
| **១. លទ្ធផលចំណូលក្នុងស្រុកសរុបជាបណ្តើរៗកាន់តែខិតទៅរកគោលដៅដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ** | ចំណូលក្នុងស្រុកសរុបសម្រេចបាន+/- ៥% ធៀបនឹងគោលដៅដែលបានអនុម័តក្នុងច្បាប់ | ចំណូលក្នុងស្រុកសម្រេចបាន÷<br>☐ត្រីមាសទី១: ២៣,៧% ធៀបនឹងច្បាប់<br>• ចំណូលចរន្ត : ២៣,៩%<br>• ចំណូលមូលធន (ក្នុងស្រុក) : ៧,៣%<br>សម្រាប់ការអនុវត្តផែនការប្រមូលចំណូលសារពើពន្ធធៀបនឹងផែនការប្រចាំត្រីមាសទី១ ÷<br>☐គយនិងរដ្ឋាករ÷ ៩៩,១០%<br>☐ពន្ធដារ÷ ១៣១,៩៥%<br>សម្រាប់ការអនុវត្តផែនការប្រមូលចំណូលមិនមែនសារពើពន្ធធៀបនឹងផែនការ÷<br>☐ទ្រព្យសម្បត្តិរដ្ឋ÷ ៥៧%<br>☐ឧស្សាហកម្មហិរញ្ញវត្ថុ ÷៨៧,៦៥% | ចំណូលក្នុងស្រុកសម្រេចបាន÷<br>☐ត្រីមាសទី១: ២៥,៥% ធៀបនឹងច្បាប់<br>• ចំណូលចរន្ត : ២៥,៦%<br>• ចំណូលមូលធន (ក្នុងស្រុក) : ១៨,០ %<br>សម្រាប់ការអនុវត្តផែនការប្រមូលចំណូលសារពើពន្ធធៀបនឹងផែនការប្រចាំត្រីមាសទី១ ÷<br>☐គយនិងរដ្ឋាករ÷ ១១១,២៦%<br>☐ពន្ធដារ÷ ១១៧,៣០%<br>សម្រាប់ការអនុវត្តផែនការប្រមូលចំណូលមិនមែនសារពើពន្ធធៀបនឹងផែនការ÷<br>☐ទ្រព្យសម្បត្តិរដ្ឋ÷ ៥២,៨២%<br>☐ឧស្សាហកម្មហិរញ្ញវត្ថុ ÷១១៩,៦០% |
| **២. គ្មានការបង្កើតឡើងនូវបំណុលកកស្ទះថ្មី (គិតរយៈពេល៦០ថ្ងៃ)** | បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២%នៃចំណាយសរុប | គ្មាន | គ្មាន |
| **៣. អាណាប័កជាបណ្តើរៗអាចបញ្ចាចំណាយទៅតាមកម្មវិធីចំណាយនិងផែនការសាច់ប្រាក់** | ស្ថានភាពចំណាយមិនត្រូវតិចជាង:<br>☐ ត្រីមាសទី១: ១៥%<br>☐ ត្រីមាសទី២: ៤៥%<br>☐ ត្រីមាសទី៣: ៦៧%<br>☐ ត្រីមាសទី៤: ៩៦%<br><br>ភាគរយនៃការទូទាត់ជូនអ្នកផ្គត់ផ្គង់និងបុគ្គលិកតាមប្រព័ន្ធធនាគារមិនត្រូវតិចជាង ៨០%នៃចំណាយសរុប | ចំណាយថវិកាជាតិសម្រេចបាន÷<br>☐ ត្រីមាសទី១: ១៥,១៦%<br><br>ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន÷<br>☐ត្រីមាសទី១: ១០០%<br>▪ ក្រសួងចំនួន ៣៦ ក្រសួងស្ថាប័នបានបើកបៀវត្សតាមប្រព័ន្ធធនាគារ | ចំណាយថវិកាជាតិសម្រេចបាន÷<br>☐ ត្រីមាសទី១: ១៤,៥៧%<br><br>ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន÷<br>☐ ត្រីមាសទី១: ១០០%<br>▪ ក្រសួងចំនួន ៣៦ ក្រសួងស្ថាប័នបានបើកបៀវត្សតាមប្រព័ន្ធធនាគារ |

| សូចនាករ | គោលដៅ | វឌ្ឍនភាពត្រីមាសទី១ ឆ្នាំ ២០១៥ | វឌ្ឍនភាពត្រីមាសទី១ ឆ្នាំ ២០១៦ |
|---|---|---|---|
| | | - ត្រីមាសទី១÷<br>-ចំណូលពន្ធគយ:<br>▪ ៩២% បង់តាមធនាគារដោយអតិថិជន<br>▪ ៨% បង់តាមធនាគារដោយគយ<br>-ចំណូលពន្ធដារ:<br>▪ ៩៨,៨% បង់តាមធនាគារដោយអតិថិជន<br>▪ ១,២% បង់តាមធនាគារដោយពន្ធដារ | ត្រីមាសទី១÷<br>-ចំណូលពន្ធគយ:<br>▪ ៩៤,២% បង់តាមធនាគារដោយអតិថិជន<br>▪ ៥,៨% បង់តាមធនាគារដោយគយ<br>-ចំណូលពន្ធដារ:<br>▪ ៩៦,៩% បង់តាមធនាគារដោយអតិថិជន<br>▪ ៣,១% បង់តាមធនាគារដោយពន្ធដារ |
| ៤. ចំណាយតាមប្រភេទកាន់តែខិតទៅរកថវិកាដែលបានអនុម័ត | លទ្ធផលចំណាយធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង÷<br>☐ បៀវត្ស: ៩៨%<br>☐ ទំនិញ/សេវា: ៩៥%<br>☐ មូលធន: ៨៥% | ចំណាយថវិកាជាតិសម្រេចបាន÷ ត្រីមាសទី១ ឆ្នាំ២០១៥÷<br>☐ បៀវត្ស: ២២,៣៤%<br>☐ ទំនិញ/សេវា: ៨,៥៤%<br>☐ មូលធន: ១២,៧៥% | ចំណាយថវិកាជាតិសម្រេចបាន: ត្រីមាសទី១ ឆ្នាំ២០១៦÷<br>☐ បៀវត្ស: ១៨,៦៤%<br>☐ ទំនិញ/សេវា: ៨,៨៨%<br>☐ មូលធន: ១៤,២៥% |
| ៥. ទិន្នផលចំណូលលើមូលដ្ឋានពន្ធកាន់តែប្រសើរជាងមុនតាមរយៈការកែលម្អប្រសិទ្ធភាពនៃការប្រមូល និងផែនការប្រើប្រាស់ប្រភពចំណូលមិនមែនសារពើពន្ធ | ការរួមចំណែកទៅក្នុង ផសស នៃ ចំណូលសរុបមានការកែលម្អដោយបង្កើនប្រមាណ ០,៥% ក្នុងមួយឆ្នាំ | ☐ចំណូលសារពើពន្ធ÷ ២៥,៥%<br>• ពន្ធផ្ទាល់: ២៨,៩%<br>• ពន្ធប្រយោល: ២៧,៥%<br>☐ចំណូលមិនមែនសារពើពន្ធ: ១៥,៦% | ☐ចំណូលសារពើពន្ធ÷ ២៧,៤%<br>• ពន្ធផ្ទាល់: ៣៣,៩%<br>• ពន្ធប្រយោល: ២៥,៨%<br>☐ចំណូលមិនមែនសារពើពន្ធ: ១៦,៧% |
| ៦. រាល់ផ្នែកសំខាន់ៗនៃចំណូល និងចំណាយសាធារណៈត្រូវបានដាក់បញ្ចូលក្នុងថវិកានិងគណនីរបស់រដ្ឋាភិបាល | មិនមានផ្នែកសំខាន់ៗដែលត្រូវបានដកចេញ | មានចំនួនគណនីសរុប÷ ៨២ គណនី | មានចំនួនគណនីសរុប÷ ៨២ គណនី |

ប្រភព÷ អគ្គនាយកដ្ឋានរតនាគារជាតិ (ទិន្នន័យបណ្ដោះអាសន្ន គិតត្រឹមថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៦)

### ១.១.១. ការអនុវត្តផែនការប្រមូលចំណូលក្នុងប្រទេស

យោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ, ចំណូលបានពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាសម្រេចបាន ១.២៦៥.០៦៤ លានរៀល ខ្ពស់ជាងផែនការប្រចាំត្រីមាសប្រមាណ ១១,២៦% ដែលស្មើនឹង ២៦,៧% នៃច្បាប់ថវិកាឆ្នាំ២០១៦។ ប្រសិនបើធៀបការអនុវត្តប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ និងត្រីមាសទី១ ឆ្នាំ២០១៥ ការអនុវត្តចំណូលមានការកើនឡើង៤១,៦០%។ តាមរយៈទិន្នន័យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (ដោយគិតតែចំណូលសារពើពន្ធ) តួលេខនៃការបង់ចំណូលគយចូលរតនាគារជាតិក្នុងត្រីមាសទី១ ឆ្នាំ២០១៦នេះ សម្រេចបាន ១.៧៧៦.៦៩៣ លានរៀល ខ្ពស់ជាងផែនការ ១១,៣៦% ដោយសារការអនុវត្តយ៉ាងម៉ឺងម៉ាត់នូវការត្រួតពិនិត្យ

ដើមទី កណ្ដាលទី និងចុងទី និងបានដាក់ឱ្យអនុវត្តផែនការសកម្មភាពនៃការប្រមូលពន្ធ អាករ និងប្រាក់ពិន័យលើយានយន្តមានស្រាប់ក្នុងប្រទេសដែលមិនបានបំពេញកាតព្វកិច្ចពន្ធ និងអាករ។

ចំពោះចំណូលបានពីអគ្គនាយកដ្ឋានពន្ធដារ (ចំណូលសារពើពន្ធថ្នាក់ជាតិ) ដោយយោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ) សម្រេចបាន ១.៤៨០.២៦៣ លានរៀល ខ្ពស់ជាងផែនការប្រចាំត្រីមាសប្រមាណ ១៧,៣០% ដែលស្មើនឹង ៣០,១៧% នៃច្បាប់ថវិកាឆ្នាំ២០១៦។ ប្រសិនបើធៀបការអនុវត្តប្រចាំត្រីមាសទី១ ឆ្នាំ ២០១៦ និងត្រីមាសទី១ ឆ្នាំ២០១៥ ការអនុវត្តចំណូលមានការកើនឡើង ៣០,១៥%។ តាមរយៈទិន្នន័យរបស់អគ្គ-នាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (ដោយគិតតែចំណូលសារពើពន្ធទាំងថ្នាក់ជាតិ) តួលេខនៃការបង់ចំណូលគយចូលរតនាគារជាតិក្នុងត្រីមាសទី១ ឆ្នាំ២០១៦នេះ សម្រេចបាន ១.៤៧៦.១៥០,៩ លានរៀល។ ចំណូលពន្ធដារកើនឡើងដោយសារ÷

- ចំណូលពន្ធលើប្រាក់ចំណេញមានការកើនឡើងខ្ពស់ជាងផែនការ ពីព្រោះ÷
    - អ្នកជាប់ពន្ធមានការយល់ដឹងពីកាតព្វកិច្ចបង់ពន្ធ តាមរយៈការបញ្ជ្រាបវប្បធម៌បង់ពន្ធជូនដល់អ្នកជាប់ពន្ធ។
    - កំណើនសេដ្ឋកិច្ចជាតិមានការកើនឡើង ដោយសារស្ថិរភាពនយោបាយ។
    - អគ្គនាយកដ្ឋានពន្ធដារបានពង្រឹងការចុះធ្វើសវនកម្មសហគ្រាស។
    - ការផ្ដល់សេវាជូនអ្នកជាប់ពន្ធកាន់តែប្រសើរតាមរយៈការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារ។
- អាករស្នាក់នៅមានការកើនឡើង ពីព្រោះមានការកើនឡើងច្រើននូវភ្ញៀវទេសចរក្នុងអំឡុងពេលត្រីមាសទី១ នេះ ។
- ពន្ធប៉ាតង់ មានការកើនឡើន ពីព្រោះប្រាក់ពន្ធមានការកើនឡើងក្នុងឆ្នាំ២០១៦។

ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានពន្ធដារនឹងដាក់ចេញនូវការកែទម្រង់ដ៏មុតស្រួច ដូចខាងក្រោម÷

- បន្តអនុវត្តប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាលនិងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- ពិនិត្យកែសម្រួលឡើងវិញនូវច្បាប់ស្ដីពីសារពើពន្ធ ដើម្បីឆ្លើយតបទៅនឹងស្ថានភាពវិវឌ្ឍនៃសង្គមជាតិ។
- ពង្រឹងការប្រមូលពន្ធលើការជួលអចលនទ្រព្យ (ដី+ផ្ទះ) តាមរយៈការដាក់ឱ្យអនុវត្តការគ្រប់គ្រងការប្រកាស បង់ពន្ធប្រភេទនេះ តាមប្រព័ន្ធកុំព្យូទ័រ។
- បន្តយកចិត្តទុកដាក់ និងពង្រឹងការចុះបញ្ជីពន្ធដារនិងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស។

ចំពោះចំណូលបានពីអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុសម្រេចបាន ២៧.៥៣៧. លានរៀល ( យោងតាមទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ ដោយមិនបានរាប់បញ្ចូលចំណូលពីអាជ្ញាប័ណ្ណកាស៊ីណូ ដែលតាមប្លង់គណនីថ្មីត្រូវបានដាក់បញ្ចូលក្នុងចំណូលអាជ្ញាប័ណ្ណ) ការអនុវត្តខ្ពស់ជាងផែនការប្រចាំត្រីមាសប្រមាណ ១៩,៦០% ដែលស្មើនឹង ២០,៤២% នៃច្បាប់ថវិកាឆ្នាំ២០១៦។ ប្រសិនបើធៀបការអនុវត្តប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ និងត្រីមាសទី១ ឆ្នាំ២០១៥ ការអនុវត្តចំណូលមានការកើនឡើង ២៩,២៩%។ តាមរយៈទិន្នន័យរបស់អគ្គនាយកដ្ឋាន

ឧស្សាហកម្មហិរញ្ញវត្ថុ ចំណូលមាន៣ ប្រភេទសំខាន់គឺ ចំណូលពីកាស៊ីណូអនុវត្តបាន ២៤.៥៧៤,៩២ លានរៀល លើសផែនការ ៨,២៦%, ចំណូលពីឆ្នោតសម្រេចបាន ៥៣១,២៧ លានរៀល លើសផែនការ ៦៣,៤៧% និង ចំណូលពីអាជ្ញាបណ្ណកាស៊ីណូអនុវត្តបាន ៤.៥៨៤,៩២លានរៀល លើសផែនការ ៩,១៦%។ សម្រាប់ចំណូលពីអាជីវកម្ម កាស៊ីណូ, ការអនុវត្តលើសផែនការនេះ ដោយសារមានក្រុមហ៊ុនមួយចំនួនបានសងបំណុលឆ្នាំចាស់ច្រើន នៅដើម ត្រីមាសទី១នេះ, សម្រាប់ ចំណូលពីអាជីវកម្មឆ្នោត ការអនុវត្តលើសផែនការនេះ ដោយហេតុថាមានក្រុមហ៊ុនឆ្នោត មួយចំនួនបានបង់បំណុលឆ្នាំចាស់ច្រើន និងសម្រាប់ចំណូលពីអាជ្ញាបណ្ណកាស៊ីណូ ការអនុវត្តលើសផែនការនេះ បណ្តាលមកពី នាយកដ្ឋានជំនាញបានជំរុញឱ្យក្រុមហ៊ុនបង់ថ្លៃអាជ្ញាបណ្ណប្រចាំឆ្នាំឱ្យអស់ត្រឹមត្រីមាសទី១នេះ។ នៅ ក្នុងត្រីមាសទី១ គណកម្មការចម្រុះដែលមានសមាសភាពមកពីអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងក្រសួង មហាផ្ទៃ បានចុះបង្ក្រាបសកម្មភាពអាជីវកម្មរបស់កាស៊ីណូ A.H.S KING GROUP Co., Ltd ក្នុងស្រុកអូរយ៉ាដាវ ខេត្ត រតនៈគិរី ដែលបានបើកធ្វើអាជីវកម្មចាប់តាំងពីខែសីហា ឆ្នាំ២០១៥ មកដោយមានលិខិតអនុញ្ញាតពីរាជរដ្ឋាភិបាល លេខ១១០៥ សជណ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ តែពុំទាន់បានទទួលអាជ្ញាបណ្ណពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅឡើយ។ ជាវិធានការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបញ្ជាឱ្យបិទកាស៊ីណូ A.H.S KING GROUP Co., Ltd។ ទន្ទឹមនេះ ក៏មានការបង្ក្រាបក្រុមហ៊ុនអាជីវកម្មកាស៊ីណូ La Grand Victore នៅប៉ោយប៉ែត ដែលបាននិងកំពុងបើក ដំណើរការអាជីវកម្មដោយមិនមានអាជ្ញាបណ្ណពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងដែលពុំទាន់ទូទាត់ប្រាក់បំណុលជំពាក់ រដ្ឋចំនួន ៣០,០០០ដុល្លារអាមេរិក និងការផ្ទេរសិទ្ធិកាន់កាប់អាជ្ញាបណ្ណចំនួន ២៥.០០០ ដុល្លារអាមេរិក។ ជាលទ្ធផល ក្រុមហ៊ុនកាស៊ីណូ La Grand Victore យល់ព្រមទូទាត់បំណុលដែលជំពាក់រដ្ឋ ចំនួន ៣០.០០០ ដុល្លារអាមេរិក និង ផ្ទេរសិទ្ធិកាន់កាប់អាជ្ញាបណ្ណចំនួន ២៥.០០០ ដុល្លារអាមេរិក យ៉ាងយូរត្រឹមដំណាច់ខែមីនា ឆ្នាំ២០១៦។ ទន្ទឹមនេះ គណៈកម្មការចម្រុះ ក៏បានចុះណែនាំម្ចាស់អាជីវកម្មកាស៊ីណូហេង ហេង ២ និងម្ចាស់អាជីវកម្មភ្នាល់បក្សីកីឡា ក្រោយ កាស៊ីណូ GMG ឱ្យបិទអាជីវកម្មភ្នាល់បក្សីកីឡា ដែលមានទីតាំងក្នុងខេត្តត្បូងឃ្មុំ។ ជាវិធានការបន្ត គណៈកម្មការ ចម្រុះនឹងបន្តឃ្លាំមើលចំពោះទីតាំងភ្នាល់បក្សីទាំងពីរកន្លែង និងចាត់វិធានការតាមផ្លូវច្បាប់ក្នុងករណីមិនអនុវត្តតាម ការណែនាំនេះ។

ដោយឡែក ផ្អែកលើទិន្នន័យរបស់អគ្គនាយកដ្ឋានរតនាគារជាតិ, ចំណូលមិនមែនសារពើពន្ធ (ដោយមិនគិត បញ្ចូលចំណូលពីកាស៊ីណូ និងចំណូលបានពីឆ្នោត) សម្រេចបាន ២៣២.០៩០ លានរៀល ទាបជាងផែនការប្រចាំត្រី មាសប្រមាណ ៤៧,១៨% (ការអនុវត្តចំណូលប្រចាំត្រីមាសទី១ ត្រូវបានកំណត់ស្មើនឹង ១៣,៥១% នៃច្បាប់ថវិកាឆ្នាំ ២០១៦)។ ប្រសិនបើប្រៀបធៀបការអនុវត្តប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ និងត្រីមាសទី១ ឆ្នាំ២០១៥ ការអនុវត្ត ចំណូលមានការកើនឡើងប្រមាណ១១,៩១%។ មូលហេតុដែលការអនុវត្តប្រចាំត្រីមាសទី១ អនុវត្តបានទាបជាង គ្រោងចំណូលប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ ដោយមានមូលហេតុដូចតទៅ ÷

- ***ចំណូលបានពីផលនេសាទ*** ត្រូវបានគ្រោងចំនួន ៣០៥៥ ពាន់លានរៀល នៅឆ្នាំ២០១៦។ ចំណូល ត្រូវ ប្រមូលបានមានតិចតួច ក្នុងត្រីមាសទី១នេះ ដោយសារតែកត្តាធម្មជាតិ ដូចជាបញ្ហាទឹកតូច ជាដើម និង នៅខេត្តកណ្តាល មានបញ្ហាអាជីវករមិនបង់ចំណូល នៅរដូវទី២។

- ***ចំណូលបានពីផលព្រៃឈើ*** គឺអាស្រ័យលើការប្រមូលឈើដែលត្រូវបានឈូសឆាយលើដីសម្បទានសេដ្ឋកិច្ច, ឈើដែលបានកាប់សំអាតក្នុងអាងស្តុកទឹកវារីអគ្គិសនី និងអាងទំនប់ទឹកស្រោចស្រព និងឈើដែលចាប់បានពីអ្នកប្រព្រឹត្តបទល្មើសព្រៃឈើ ជាក់ស្តែង។
- ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ នឹងត្រូវបង់ភាគលាភចូលថវិការដ្ឋ ចាប់ពីខែមិថុនា ឬខែកក្កដា ដែលនាំឱ្យមិនទាន់មានចំណូលក្នុងត្រីមាសទីមួយនេះនៅឡើយទេ។
- ***សម្បទានពីប្រេងកាត និងរ៉ែ*** នៅមិនទាន់បានផ្តល់ចំណូលចូលរដ្ឋនៅឡើយ ដោយសារតែការងារប្រេងកាតកំពុងតែត្រូវបានដំណើរការរៀបចំឯកសារនិងកិច្ចព្រមព្រៀង។ ចំពោះចំណូលបានពីរ៉ែ គឺបានមកពីសួយសារ, ឈ្នួលផ្ទៃក្រឡា, កម្រៃអាជ្ញាប័ណ្ណរុករកនិងធ្វើអាជីវកម្មលើវត្ថុធាតុដើមសំភារៈសំណង់ និងសួយសារសម្បទានរ៉ែឧស្សាហកម្ម (លោហធាតុ, ថ្មមានតម្លៃ ជាដើម) ដែលចំណូលទាំងនេះថយចុះដោយសារក្រសួងរ៉ែនិងថាមពល ដែលជាក្រសួងសាមីកំពុងធ្វើកំណែទម្រង់លើយន្តការចាត់ចែងនិងគ្រប់គ្រងការធ្វើអាជីវកម្មលើវិស័យនេះ ដូចជាការធ្វើប្រតិភូកម្មទៅមន្ទីរជំនាញ និងការផ្តល់អាជ្ញាប័ណ្ណ។ នីតិវិធីថ្មីនេះ មិនអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួម ក្នុងការវាយតម្លៃការបង់សួយសារឡើយ។
- ***ការជួលអចលនវត្ថុ*** ÷ បើពិនិត្យទិដ្ឋភាពជារួម, ការជួលអចលនវត្ថុមិនមានការកើនឡើងនោះទេ ដោយសារទីតាំងមួយចំនួនត្រូវបានរាជរដ្ឋាភិបាល អនុញ្ញាតគោលការណ៍ឱ្យធ្វើឯកជនភាវូបនីយកម្ម ក្រោមរូបភាពដោះដូរ និងលក់ផ្តាច់។ ចំណូលត្រូវបានបង់ជាបន្តបន្ទាប់តាមការកំណត់នៃកិច្ចសន្យា ឬមានការបង់យឺតយ៉ាវបន្តិចបន្តួច ប៉ុន្តែនឹងគ្រប់ចំនួននៅដំណាច់ឆ្នាំ
- ***ផលទុនរបស់អាកាសចរណ៍ស៊ីវិល សំដៅដល់ចំណូលបានពីថ្លៃទិញ*** សំបុត្រយន្តហោះ។ ចំណូលធ្លាក់ចុះដោយសារភ្ញៀវទេសចរណ៍មកលេងកម្ពុជាមានការធ្លាក់ចុះ ដែលនាំឱ្យការទិញសំបុត្រយន្តហោះមានការធ្លាក់ចុះ។
- ***ផលទុននៃសកម្មភាពទេសចរណ៍*** គឺបានមកពីចំណូលដែលបានពីថ្លៃទិញសំបុត្រចូលទស្សនាតំបន់អង្គរពីភ្ញៀវអន្តរជាតិ។ ចំណូលនេះ មានការធ្លាក់ចុះដោយសារភ្ញៀវទេសចរណ៍មានការថយចុះ។
- ផលទុនរបស់ប្រៃសណីយ៍និងទូរគមនាគមន៍ មានការធ្លាក់ចុះដោយសារចំណូលនេះនៅមានបំណុលដែលក្រុមហ៊ុននៅជំពាក់ នៅមិនទាន់បានបង់នៅឡើយ។
- ***អាករនៃស្ថានទូត*** រួមមាន ការផ្តល់ទិដ្ឋាការស្ទិ៊ត ការផ្តល់ទិដ្ឋាការអេឡិចត្រូនិច ការផ្តល់លិខិតឆ្លងដែនដោយក្រសួងមហាផ្ទៃ និងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។ ចំណូលប្រភេទនេះ មានការថយចុះ ដោយសារការធ្វើលិខិតឆ្លងដែនមានការធ្លាក់ចុះ។

### ១.១.២. បំណុលកកស្ទះ

គ្មានការបង្កើតឡើងនូវបំណុលកកស្ទះថ្មី បើគិតរយៈពេល៦០ថ្ងៃ ចាប់ពីអាណត្តិបើកផ្តល់ប្រាក់ បានចូលរតនាគារជាតិរហូតដល់ថ្ងៃទូទាត់។ នេះបង្ហាញថាដំណើរការទូទាត់ មានលក្ខណៈល្អប្រសើរជាងមុន និងខិតជិតទៅរកនិយាមអន្តរជាតិនៃការកំណត់បំណុលកកស្ទះ។

### ១.១.៣. ចំណាយថវិកាជាតិ

ការអនុវត្តចំណាយសម្រាប់ត្រីមាសទី១ គឺសម្រេចបាន ១៤,៥៧% នៃច្បាប់ ពោលគឺទាបជាង ០,៤៣%។ ការអនុវត្តទាបជាងគោលដៅ ព្រោះការរៀបចំរជ្ជទេយ្យបុរេប្រទានទៅតាមទម្រង់រជ្ជទេយ្យបុរេប្រទានថ្មីមានភាពយឺតយ៉ាវសម្រាប់ថ្នាក់មូលដ្ឋាន រីឯទម្រង់អាណត្តិថ្មីតម្រូវឱ្យមានការបំពេញលេខតាមកម្មវិធី-អនុកម្មវិធី-ចង្កោមសកម្មភាព។ ម្យ៉ាងទៀត នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៦ នេះ ក្រសួង-ស្ថាប័នបានសម្រុកចំណាយកញ្ចប់ថវិកាឆ្នាំចាស់ ដែលធ្វើប៉ះពាល់ដល់លទ្ធភាពចំណាយឆ្នាំថ្មី។

ក្រសួង-ស្ថាប័នមួយចំនួន ដែលអនុវត្តថវិកាបានតិចជាង ១៥% ធៀបនឹងច្បាប់ថវិកាសម្រាប់ត្រីមាសទី១ ឆ្នាំ២០១៥ មានដូចតទៅ÷

១. ក្រសួងមុខងារសាធារណៈ អនុវត្តបាន ៩,៤៤%

២. ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អនុវត្តបាន ០%

៣. មហាផ្ទៃ (រដ្ឋបាលទូទៅ) អនុវត្តបាន ១០,៣៥%

៤. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អនុវត្តបាន ១,៨២%

៥. អាជ្ញាធរសវនកម្មជាតិ អនុវត្តបាន ១១,២៨%

៦. ក្រសួងសុខាភិបាល អនុវត្តបាន ៨,១៦%

៧. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អនុវត្តបាន ១១,៤២%

៨. ក្រសួងបរិស្ថាន អនុវត្តបាន ១១,៦៣%

៩. ក្រសួងធម្មការ និងសាសនា អនុវត្តបាន១៣,៥៩%

១០. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តបាន៧,៤៨%

១១. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុវត្តបាន៣,៤៨%

១២. ក្រសួងរ៉ែនិងថាមពល អនុវត្តបាន៩,០៩%

១៣. ក្រសួងពាណិជ្ជកម្ម អនុវត្តបាន១១,៩០%

១៤. ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អនុវត្តបាន ១០,២៧%

១៥. ក្រសួងអភិវឌ្ឍន៍ជនបទ អនុវត្តបាន១,៩៤%

១៦. ក្រសួងប្រៃសណីយ៍ អនុវត្តបាន ៧,០៨%

១៧. ក្រសួងសាធារណៈការ និងដឹកជញ្ជូន អនុវត្តបាន ៧,១៦%

១៨. ក្រសួងរៀបចំដែនដី នគរូបណីយកម្ម និងសំណង់ អនុវត្តបាន ១០,៤៧%

២៩. ក្រសួងធនធានទឹក និងឧតុនិយម អនុវត្តបាន ១,៩៩% និង

២០. ក្រសួងឧស្សាហកម្មនិងសិប្បកម្ម អនុវត្តបាន ១១,៣១%។

ដោយឡែក រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី-ខេត្ត, ក្រុង-ស្រុក និងឃុំ-សង្កាត់) អនុវត្តបាន ៨,៣៦%។

ទន្ទឹមនេះ មន្ទីរជំនាញនៃក្រសួង-ស្ថាប័នអនុវត្តថវិកាកម្មវិធី នៅមិនទាន់បានធ្វើការទូទាត់រជ្ជទេយ្យបុរេប្រទានជុំទី១ នៅឡើយ ដោយសារមូលហេតុដូចជា÷

- ☐ មានភាពយឺតយ៉ាវក្នុងការរៀបចំបង្កើតតារាងរដ្ឋទេយ្យបុរេប្រទាន
- ☐ ការទូទាត់ជួបការលំបាក ព្រោះត្រូវធ្វើឡើងតាមកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ដែលតម្រូវឱ្យធ្វើការបោះផ្សាយអាណត្តិច្រើន (តាមគម្រូអាណត្តិបើកប្រាក់ថ្មី) ។ ទោះយ៉ាងណា បញ្ហានេះ នឹងត្រូវបានដោះស្រាយនៅក្នុងត្រីមាសទី២ នេះ ដោយហេតុថាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទើបចេញសេចក្តីណែនាំអំពីការបង្កើតតារាងឧបសម្ព័ន្ធសម្រាប់ភ្ជាប់អាណត្តិបើកប្រាក់របស់មន្ទីរអនុវត្តថវិកាកម្មវិធី ក្នុងករណីអាណត្តិមួយមានចង្កោមសកម្មភាពច្រើន។
- ☐ រីឯការធានាចំណាយ មិនមានជួបប្រទះបញ្ហាឡើយ ដោយហេតុថាមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានផ្តល់ទិដ្ឋាការលើធានាចំណាយជូនដល់មន្ទីរជំនាញស្ទើរតែ ១០០% រួចហើយ។ ដោយឡែកចំពោះកិច្ចលទ្ធកម្មវិញនៅថ្នាក់មូលដ្ឋាន, មន្ទីរជំនាញ ១០ ដែលបានចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញក្នុងឆ្នាំ២០១៥ មិនបានជួបប្រទះ បញ្ហាអ្វីទេ ចំណែកឯ មន្ទីរជំនាញថ្មីទាំង ១៥ ដែលទើបចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញក្នុងឆ្នាំ២០១៦នេះ ជួបប្រទះការលំបាកក្នុងការអនុវត្តនីតិវិធីថ្មី ដោយត្រូវបង្កើតក្រុមលទ្ធកម្មថ្មី និងត្រូវអនុវត្តកិច្ចលទ្ធកម្មដោយខ្លួនឯងផ្ទាល់។
- ☐ ភាពយឺតយ៉ាវនៃការទទួលបានអាណាប័កផ្ទេរសិទ្ធិ។

#### ១.១.៤. ចំណាយតាមប្រភេទ

ចំណាយតាមប្រភេទសម្រេចបាន ដូចតទៅ÷ បៀវត្ស មាន ១៨,៦៤%, ទំនិញ/សេវា មាន ៨,៨៥% និងមូលធន មាន ១៤,២៥%។

### ១.២. លទ្ធផលនៃសកម្មភាពគន្លឹះសម្រាប់បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា

**ផ្នែកទី១÷ ភាពជឿទុកចិត្តនៃថវិកា** ត្រូវបានបន្តអនុវត្តដោយមានគោលបំណងចំនួន ៤ និងចង្កោមសកម្មភាពចំនួន១៤។ គោលបំណងចំនួន ៤ រួមមាន÷ (១) បន្តពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល, (២) បន្តពង្រឹងការគ្រប់គ្រងបំណុល, (៣) ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី, (៤) កែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ។ ភាពជឿទុកចិត្តនៃថវិកា គឺជាលទ្ធផលចុងក្រោយ (OUTCOME) នៃការអនុវត្តការងារកែទម្រង់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការសម្រេចបាននូវភាពជឿទុកចិត្តនៃថវិកា គឺជាគន្លឹះដើម្បីធានាឱ្យការវិភាជប្រកបដោយប្រសិទ្ធភាព, វិន័យថវិកា និងស័ក្តិសិទ្ធភាពការផ្តល់សេវាសាធារណៈ ព្រមទាំងរក្សាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

ក្នុងត្រីមាសទី១ នេះ មានសកម្មភាពគ្រោងអនុវត្តដោយអង្គភាពចំនួន ០៩ រួមមាន អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, អគ្គលេខាធិការដ្ឋាននៃ គសហវ និងក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ (FMWG)។

### ១.២.១. ការបន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល

គោលបំណងនេះមាន ០៣ ចង្កោមសកម្មភាព ដែលត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានចំនួន ៦ គឺ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ, អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ និងអគ្គលេខាធិការដ្ឋាននៃ កសហវ។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន, គោលបំណងនេះសម្រេចបាន ៨៨% ក្នុងនោះ ចង្កោម សកម្មភាព ១១.១. អនុវត្តគោលនយោបាយចំណូលរយៈពេលមធ្យម និងយុទ្ធសាស្ត្រកៀរគរចំណូល សម្រេចបាន ៧៨%, ចង្កោមសកម្មភាព ១១.២ បន្តកែលម្អគោលនយោបាយនិងរដ្ឋបាលគយ, ពន្ធដារ និងចំណូលមិនមែនសារពើពន្ធ និងទ្រព្យសម្បត្តិរដ្ឋ សម្រេចបាន ៨៨%, ចង្កោមសកម្មភាព ១១.៣. ពង្រឹងការព្យាករចំណូល សម្រេចបាន ៩៧%។

ជាក់ស្តែង បើពិនិត្យមើលលទ្ធផលសម្រេចបាននៃចង្កោមសម្មភាពទាំង០៣ ឃើញថាមានសូចនាករសំខាន់ៗ ចំនួន ១១ សម្រេចបានតាមគោលដៅរួមមាន÷

១. របាយការណ៍ត្រួតពិនិត្យតាមដានការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ផ្នែកចំណូលសារពើពន្ធប្រចាំឆ្នាំ២០១៥ ត្រូវបានរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំ។

២. ម៉ូដែលព្យាករណ៍ របស់អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ត្រូវបានសិក្សាគម្លាត (មានជារបាយការណ៍សិក្សាគម្លាត)។

៣. ប្រព័ន្ធទិន្នន័យតម្លៃគិតពន្ធគយ ៣ ជំពូកត្រូវបានធ្វើបច្ចុប្បន្នកម្ម។ វឌ្ឍនភាពជាក់ស្តែង សម្រេចបាន រហូតដល់១៥ ជំពូក។

៤. ប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយ ត្រូវបានពង្រីកវិសាលភាពទៅកាន់ការិយាល័យគយ ០១ បន្ថែមទៀត (ជាវឌ្ឍនភាពជាក់ស្តែង ប្រព័ន្ធទិន្នន័យគ្រប់គ្រងហានិភ័យគយត្រូវបានដាក់ឱ្យដំណើរការចំនួន ០២ ការិយាល័យបន្ថែមទៀត (ការិយាល័យគយនិងរដ្ឋាករផែស្ងួត អ៊ុយញ៉ុង និងការិយាល័យគយនិងរដ្ឋាករផែស្ងួត សុកន)។

៥. សេចក្តីព្រាងសារាចរណែនាំស្តីពីការអនុវត្តការស៊ើបអង្កេតបទល្មើសសារពើពន្ធត្រូវបានរៀបចំក្នុងកម្រិតក្រុមការងារ។

៦. ចំណាត់ថ្នាក់ស្តង់ដារសកម្មភាពអាជីវកម្មសម្រាប់ប្រើប្រាស់នៅអគ្គនាយកដ្ឋានពន្ធដារ ឱ្យស្របតាមស្តង់ដារអន្តរជាតិ សម្រាប់រៀបចំម៉ូដែលព្យាករណ៍ និងវិភាគចំណូលត្រូវបានរៀបចំ។

៧. បញ្ជីអ្នកជាប់ពន្ធចរន្ត និងបញ្ជីអ្នកជាប់ពន្ធចរន្តដែលបាត់ខ្លួន មិនមកដាក់លិខិតប្រកាស ត្រូវបានរៀបចំ។

៨. យន្តការនៃការបង្កើតការិយាល័យផ្តល់ព័ត៌មានតាមទូរសព្ទសិក្សា និងយន្តការសម្រាប់ផ្តល់សេវាពិគ្រោះយោបល់នៅបញ្ជរពិគ្រោះយោបល់នៅតាមសាខាពន្ធ ត្រូវបានរៀបចំ។

៩. តាមដាននិងត្រួតពិនិត្យការផ្ទេរអ្នកជាប់ពន្ធរបបម៉ៅការ តាមសាខាពន្ធដារខណ្ឌទាំងអស់ដើម្បីផ្ទេរចូលរបបស្វ័យប្រកាស (ចុះអង្កេតស្រាវជ្រាវតាមដងផ្លូវនូវសហគ្រាស ដែលមានផលរបរប្រចាំឆ្នាំដែលអាចបញ្ចូលក្នុងរបបស្វ័យប្រកាស និងបានស្នើសុំសាខាពន្ធដារឱ្យដាក់សហគ្រាសដែលស្ថិតក្នុងរបបម៉ៅការចំនួន ១.៣៤៥ សហគ្រាស ឱ្យស្ថិតនៅក្នុងរបបស្វ័យប្រកាស)។

១០. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ត្រូវបានឆ្លងកិច្ចប្រជុំជាមួយលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម។

១១. សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវបានរៀបចំកម្រិតអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

ដោយឡែក មានសូចនាករចំនួន ០៣ មិនបានសម្រេចតាមគោលដៅគ្រោងទុក គឺ ÷

១. នីតិវិធីបញ្ចេញទំនិញពីគយមុនពេលទំនិញមកដល់ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តដូចការគ្រោងទុក (សម្រេចបានត្រឹម ៥០%)។

២. អនុក្រឹត្យស្តីពីការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលចំនួន១០ ត្រូវបានរៀបចំ ប៉ុន្តែគ្រឹះស្ថានសាធារណៈរដ្ឋបាលមួយចំនួនមានការតវ៉ាក្នុងការអនុវត្តព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥។ មូលហេតុនៃការតវ៉ា គឺ (១) គ្រឹះស្ថានសាធារណៈមួយចំនួន ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ, (២) ការបើកគណនីប្រាក់បញ្ញើនៅធនាគារជាតិ, និង (៣) សមាសភាពក្រុមប្រឹក្សាភិបាលប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ទោះបីយ៉ាងក៏ដោយ ក្រុមការងាររៀបចំវិសោធនកម្មច្បាប់ និងកែប្រែលិខិតបដ្ឋានសម្រាប់គ្រប់គ្រងសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាលបាននិងកំពុងពិភាក្សាជាមួយគ្រឹះស្ថានសាធារណៈរដ្ឋបាលដោះស្រាយបញ្ហាខាងលើ និងពន្លឿនការរៀបចំអនុក្រឹត្យបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលឱ្យបានទាន់ពេលវេលា។

៣. ឯកសារសិក្សាស្រាវជ្រាវអំពីបច្ចេកទេសល្បែង និងវិធាននៃការលេងល្បែងតាមអ៊ីនធើណែតត្រូវបានរៀបចំ (សម្រេចបាន ៨០% ដោយសារកង្វះថវិកាក្នុងការសិក្សាស្រាវជ្រាវ)។

ទន្ទឹមនេះ ការអនុវត្តជាក់ស្តែងនិងផែនការប្រមូលចំណូល មានគម្លាតធំជាង +/-៥%នៅឡើយ បង្ហាញថាភាពរលូននៃថវិកានៅមានកម្រិតនៅឡើយ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ មិនបានរៀបចំសកម្មភាពសម្រាប់ការបង្កើតម៉ូដែលព្យាករណ៍ចំណូលនោះទេ។ ក្នុងន័យនេះ អគ្គនាយកដ្ឋានទាំងពីរ គួរពិនិត្យលទ្ធភាពលើការរៀបចំឧបករណ៍ព្យាករណ៍នេះ ឱ្យបានរួចរាល់ក្នុងឆ្នាំ២០១៦នេះ។ ទោះយ៉ាងណាក៏ដោយ អង្គភាពប្រមូលចំណូលបានខិតខំប្រឹងប្រែងអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលដើម្បីសម្រេចបានគោលដៅកំណើន ០,៥ ពិន្ទុភាគរយនៃផលិតផលក្នុងស្រុក។

ជាសន្និដ្ឋាន គោលបំណងនេះសម្រេចបាន ៨៨%។ លទ្ធផលនេះឆ្លុះបញ្ចាំងតាមរយៈការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ទន្ទឹមនឹងត្រូវពង្រឹងការអនុវត្តសកម្មភាពដែលមិនទាន់សម្រេចបាននៅត្រីមាសទី១នេះបន្តទៀត ជាពិសេស ការពង្រឹងការរៀបចំម៉ូដែលព្យាករណ៍ចំណូល និងការរៀបចំផែនការប្រមូលចំណូលប្រចាំត្រីមាស។

### ១.២.២. ការបន្តពង្រឹងការគ្រប់គ្រងបំណុល

គោលបំណងនេះមាន ០៣ ចង្កោមសកម្មភាព ដែលត្រូវបានអនុវត្តដោយអង្គភាពចំនួន ៤ គឺ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានថវិកា និងអគ្គលេខាធិការដ្ឋាននៃ កសហវ ។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន, គោលបំណងនេះសម្រេចបាន ៧៣% ដែលក្នុងនោះ ចង្កោមសកម្មភាព ១២.១.

អនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុលប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព សម្រេចបាន ៩៣%, ចង្កោមសកម្មភាព ១២.២. រៀបចំក្របខ័ណ្ឌគតិយុត្ត និងយន្តការសម្រាប់អនុវត្តការធានារបស់រដ្ឋ សម្រេចបាន ៥០%, ចង្កោមសកម្មភាព ១២.៣. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលត្រូវទារក្នុងឆ្នាំ សម្រេចបាន ៧០%។

ជាក់ស្តែង បើពិនិត្យមើលលទ្ធផលសម្រេចបាននៃចង្កោមសកម្មភាពទាំង ០៣, មានសូចនាករចំនួន ០៣ សម្រេចបានរួមមាន ÷

១. សេចក្តីព្រាងបឋមស្តីពីគោលនយោបាយស្តីពីការធានារបស់រដ្ឋត្រូវបានរៀបចំ។

២. កម្មវិធីបណ្តុះបណ្តាលការគ្រប់គ្រង និងបណ្តុះបណ្តាលបំណុលពន្ធត្រូវបានរៀបចំ។

៣. សេចក្តីព្រាងសៀវភៅណែនាំស្តីពីសវនកម្មផ្ទៃក្នុងពន្ធដារត្រូវបានបញ្ចប់ត្រឹមកម្រិតក្រុមការងារ។

ដោយឡែក មានសូចនាករ ០១ មិនបានសម្រេចតាមគោលដៅគឺ ÷ គោលការណ៍និងលិខិតបទដ្ឋានណែនាំស្តីពីការធ្វើសវនកម្មផ្ទៃក្នុងត្រូវបានសិក្សា (សម្រេចបាន ៨០%) និង របាយការណ៍, អនុសាសន៍, បញ្ហាប្រឈមស្តីពីការគ្រប់គ្រងបំណុលមិនមែនសារពើពន្ធត្រូវទារក្នុងឆ្នាំត្រូវបានរៀបចំ (មិនមានវឌ្ឍនភាព)។

ជារួម អាចសន្និដ្ឋានបានថា ការគ្រប់គ្រងបំណុលត្រូវទារនិងបំណុលត្រូវសង មានវឌ្ឍនភាពល្អ ដោយហេតុថាអង្គភាពពាក់ព័ន្ធបាននិងកំពុងពង្រឹងការតឹងទារបំណុល និងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងបំណុល។ បន្ថែមលើនេះ តម្លាភាពនៃការគ្រប់គ្រងបំណុល និងការប្រើប្រាស់ថវិកាក៏ត្រូវបានបង្កើនផងដែរ។

**១.២.៣. ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនី**

គោលបំណងនេះមាន ០៥ ចង្កោមសកម្មភាព ដែលត្រូវបានអនុវត្តដោយអង្គភាពចំនួន ៣ គឺអគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានថវិកា និងក្រុមការងារគ្រប់គ្រងគម្រោង FMIS។ ផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៩៦% ក្នុងនោះចង្កោមសកម្មភាព ១៣.១. បន្តកែលម្អ និងពង្រឹងការរៀបចំផែនការសាច់ប្រាក់ សម្រេចបាន ៩០%, ចង្កោមសកម្មភាព ១៣.២. បន្តពង្រឹងការប្រើប្រាស់ប្រព័ន្ធធនាគារព្រមទាំងសិក្សានិងពិនិត្យលទ្ធភាពឈានទៅអនុវត្តការទូទាត់តាម E-Transfer សម្រេចបាន ៩០%, ចង្កោមសកម្មភាព ១៣.៣. រៀបចំយន្តការប្រមូលផ្តុំនិងបូកសរុបរបាយការណ៍អនុវត្តថវិកាគម្រោងរបស់ដៃគូអភិវឌ្ឍន៍ ដែលនៅក្រៅប្រព័ន្ធរតនាគារជាជំហានៗ និងបន្តពង្រឹងគណនីទោលរតនាគារ សម្រេចបាន ១០០%, ចង្កោមសកម្មភាព ១៣.៤. បន្តតាមដានបំណុលកកស្ទះ និងអាយុកាលរបស់វា សម្រេចបាន ១០០%, ចង្កោមសកម្មភាព ១៣.៥. ទូទាត់បុរេប្រទានឱ្យបានទាន់ពេលវេលា សម្រេ ចបាន ១០០%។

ជាក់ស្តែង បើពិនិត្យមើលលទ្ធផលសម្រេចបាននៃចង្កោមសម្មភាពទាំង ០៥, មានសូចនាករចំនួន ៣ សម្រេច បានតាមគោលដៅ÷

១. មុខងារទូទាត់តាម EFT (Electronic Fund Transfer) នៅក្នុងប្រព័ន្ធ FMIS ត្រូវបានធ្វើសន្ទានកម្មជាមួយធនាគារជាតិ និងធ្វើការសាកល្បងក្នុងកម្រិតបច្ចេកទេសរួចរាល់រួមជាមួយទាំងសុវត្ថិភាព (ក្រុមការងារ FMIS)

២. ព័ត៌មានរបាយការណ៍ចំណូល និងចំណាយពីអង្គភាពពាក់ព័ន្ធត្រូវបានប្រមូលផ្តុំ និងរៀបចំតាមរយៈការប្រមូលតាមដានពិនិត្យ និងព្យាករណ៍ស្ថានភាពចំណូល និងចំណាយរបស់ក្រសួង-ស្ថាប័ន។

៣. ទម្រង់របាយការណ៍អនុវត្តថវិកាគម្រោងរបស់ដៃគូអភិវឌ្ឍន៍ត្រូវបានរៀបចំ និងផ្សព្វផ្សាយអនុវត្តតាមរយៈការរៀបចំសេចក្តីណែនាំដល់ក្រសួង-ស្ថាប័នអនុវត្តគម្រោងហិរញ្ញប្បទាន ដោយដៃគូអភិវឌ្ឍន៍ឱ្យធ្វើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំស្របតាម COA របស់រាជរដ្ឋាភិបាល។

ដោយឡែក មានសូចនាករចំនួន ១ មិនសម្រេចបានតាមគោលដៅគ្រោងទុក គឺ÷

១. ប្រព័ន្ធ Online Web-based Application ត្រូវបានប្រើប្រាស់សាកល្បងពេញលេញដោយក្រសួងចំនួន ៨ ក្នុងចំណោមក្រសួង ១០ (សម្រេចបាន៨០%)។

ជារួម ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងគណនីបាននិងកំពុងមានដំណើរការល្អគួរឱ្យកត់សម្គាល់នៅក្នុងត្រីមាសទី១។ ទោះបីជាយ៉ាងណា ការទូទាត់តាមប្រព័ន្ធ E-Transfer នៅក្នុងប្រព័ន្ធ FMIS មិនទាន់ត្រូវបានដាក់ឱ្យអនុវត្ត ដែលគួរមានការយកចិត្តទុកដាក់ខ្ពស់បន្ថែមទៀតដើម្បីអាចបញ្ចប់នៅក្នុងត្រីមាសបន្ទាប់ និងការពង្រីកការអនុវត្តសាកល្បងនូវប្រព័ន្ធ Online Web-based Application ដែលអាចជួយដល់ការរៀបចំផែនការសាច់ប្រាក់។

### ១.២.៤. ការកែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ

គោលបំណងនេះមាន ០៣ ចង្កោមសកម្មភាព ដែលត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានចំនួន ៣ គឺ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ, អគ្គលេខាធិការដ្ឋាននៃគសហវ, និងក្រុមការងារគ្រប់គ្រងគម្រោង FMIS។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន, គោលបំណងនេះសម្រេចបាន ៨៨% ដែលក្នុងនោះចង្កោមសកម្មភាព ១៤.១. ការធ្វើសុខដុមនីយកម្មរវាងការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ (IRRPP) និងស្តង់ដារនីតិវិធីរួម (SOP/PM) សម្រេចបាន ៩០%, ចង្កោមសកម្មភាព ១៤.២ បង្កើនការប្រកួតប្រជែង និងតម្លាភាពក្នុងដំណើរការលទ្ធកម្មដោយមានការចូលរួមជាសាធារណៈ សម្រេចបាន ៧១%, ចង្កោមសកម្មភាព ១៤.៣. រៀបចំផែនការចំណាយប្រចាំត្រីមាសឱ្យមានសុក្រឹតភាព សម្រេចបាន ១០០%។

ជាក់ស្តែង បើពិនិត្យមើលលទ្ធផលសម្រេចបាននៃចង្កោមសម្មភាពទាំង ០២, មានសូចនាករចំនួន ២ សម្រេចបាន រួមមាន÷

១. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ, សេចក្តីជូនដំណឹងការដេញថ្លៃ, ផែនការលទ្ធកម្ម និងការផ្តល់កិច្ចសន្យាត្រូវបានផ្សព្វផ្សាយលើគេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

២. កម្មវិធីចំណូល-ចំណាយតាមប្រព័ន្ធ Worksheet ត្រូវបានរៀបចំ។

ដោយឡែក មានសូចនាករចំនួន ៣ មិនបានសម្រេចតាមគោលដៅគ្រោងទុក គឺ ÷

១. សៀវភៅណែនាំស្តីពីការត្រួតពិនិត្យកិច្ចលទ្ធកម្មតាមក្រោយ (Procurement Post Review Manual) ត្រូវបានរៀបចំ (សម្រេចបាន ៩០%)

២. សេចក្តីព្រាងអនុក្រឹត្យស្តីពីបែបបទ និងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ា និងវិវាទលទ្ធកម្មមិនទាន់បានអនុម័តដោយថ្នាក់ដឹកនាំ គសហវ (សម្រេចបាន ៧០%),

៣. សេចក្តីព្រាងទី១ ប្រកាសស្តីពីបុរេលក្ខណៈសម្បត្តិអ្នកដេញថ្លៃមិនត្រូវបានសម្រេចតាមការគ្រោងទុក (សម្រេចបានសេចក្តីព្រាងបឋម), សេចក្តីព្រាងទី២ ប្រកាសស្តីពីការធ្វើចំណាត់ប្រភេទ និងចំណាត់ថ្នាក់អ្នកដេញថ្លៃមិនត្រូវបានសម្រេចតាមការគ្រោងទុក (សេចក្តីព្រាងទី១), សេចក្តីព្រាងទី២ ប្រកាសស្តីពីវិធីនៃការចុះ ការជម្រះ និង

ការផ្សព្វផ្សាយបញ្ជីខ្មៅត្រូវបានរៀបចំ (សេចក្ដីព្រាងបឋម), សេចក្ដីព្រាងទី១ ប្រកាសស្ដីពីបែបបទ និងនីតិវិធីនៃការប្ដឹង និងការដោះស្រាយបណ្ដឹងតវ៉ា និងវិវាទលទ្ធកម្មត្រូវបានរៀបចំ (សេចក្ដីព្រាងបឋម), សេចក្ដីព្រាងទី២ ប្រកាសស្ដីពីការគ្រប់គ្រងកិច្ចសន្យាត្រូវបានរៀបចំ (សេចក្ដីព្រាងបឋម) ចំណែកឯសេចក្ដីព្រាងទី២ នៃប្រកាសស្ដីពីនីតិវិធីវាយតម្លៃសំណើដេញថ្លៃត្រូវបានរៀបចំតាមគោលដៅ។ ដោយឡែកសេចក្ដីព្រាងប្រកាសស្ដីពីនីតិវិធីលទ្ធកម្មទំនិញ សំណង់ សេវាកម្ម និងសេវាទីប្រឹក្សា ត្រូវបានកំពុងប្រជុំពិនិត្យពិភាក្សាក្នុងអគ្គនាយកដ្ឋាន (សម្រេចបានប្រមាណ ៦០%)។

នៅក្នុងគោលបំណងទី១៤នេះ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានដើរតួសំខាន់ដើម្បីសម្រេចឱ្យនូវសូចនាករគន្លឹះក្នុងផែនការសកម្មភាពរួមដំណាក់កាលទី៣។ ការគ្រប់គ្រងលទ្ធកម្មសាធារណៈ គឺជាឧបករណ៍គោលនយោបាយដ៏សំខាន់មួយនិងចាំបាច់មិនអាចខ្វះបាន ក្នុងការធានាប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាជាតិឱ្យឆ្លើយតបបានទៅនឹង គោលនយោបាយរបស់រាជរដ្ឋាភិបាល។ អង្គភាពលទ្ធកម្មត្រូវយល់ដឹងច្បាស់លាស់អំពីច្បាប់ បទប្បញ្ញត្តិ និងលិខិតគតិយុត្តពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន។ ដូចនេះ ចាំបាច់ត្រូវកសាង និងពង្រឹងសមត្ថភាពដល់មន្ត្រីអង្គភាពលទ្ធកម្មនៃអង្គភាពថវិកា ដើម្បីធានាឱ្យដំណើរការនៃការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ប្រព្រឹត្តទៅដោយរលូន មានតម្លាភាពគណនេយ្យភាព ភាពយុត្តិធម៌ ការសន្សំសំចៃ និងឆ្លើយតបតាមតម្រូវការបានទាន់ពេលវេលានៅតាមក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។

ទោះយ៉ាងណា អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបានធ្វើការបណ្ដុះបណ្ដាល និងផ្សព្វផ្សាយដល់ក្រុមការងារលទ្ធកម្មសាធារណៈរបស់ក្រសួង ស្ថាប័ន និងគ្រូបង្គោល ជាច្រើនលើកច្រើនសារមកហើយដែលរួមមានដូចជា÷

- នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ បានផ្សព្វផ្សាយអនុក្រឹត្យស្ដីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម និងប្រកាសស្ដីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកាជូនដល់សិក្ខាកាមចូលរួមសិក្ខាសាលាចំនួន ១៥៧នាក់ ដែលបានអញ្ជើញមកពីតំណាងក្រសួង-ស្ថាប័ន សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។
- នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ បានផ្សព្វផ្សាយអនុក្រឹត្យស្ដីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្មនិងអង្គភាពលទ្ធកម្ម និងប្រកាសស្ដីពីការបង្កើតក្រុមលទ្ធកម្មរបស់អង្គភាពថវិកាជូនដល់សិក្ខាកាមចូលរួមសិក្ខាសាលាចំនួនសិក្ខាកាមចំនួន ៣៨៩នាក់ ដែលបានអញ្ជើញមកពីតំណាងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ប្រធានមន្ទីរជំនាញរាជធានី ខេត្តនៃក្រសួងអនុវត្តថវិកាកម្មវិធីទាំង ១០ តំណាងអគ្គនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រធានរតនាគាររាជធានីខេត្ត។
- បានបណ្ដុះបណ្ដាលមន្ត្រីលទ្ធកម្មរបស់អង្គភាពថវិកាស្ដីពីជំនាញលទ្ធកម្មសាធារណៈ នៃក្រសួង-ស្ថាប័ន អនុវត្តថវិកាកម្មវិធីទាំង១០ ចាប់ពីថ្ងៃទី១៨ ឧសភា ដល់ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥ មានសិក្ខាកាមចូលរួមមកដល់ពេលនេះមានចំនួន ៧៦ នាក់។
- បានបណ្ដុះបណ្ដាលបំពាក់បំប៉នដល់គ្រូបង្គោលមកពីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីខេត្ត នៅថ្ងៃទី៣០ ខែមីនា ដល់ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ មានសិក្ខាកាមចូលរួមចំនួន៧២នាក់ សម្រាប់បណ្ដុះបណ្ដាលបន្ត ដល់ក្រុមលទ្ធកម្មរបស់អង្គភាពថវិកានៅតាមរាជធានីខេត្តរៀងៗខ្លួន ចាប់ពីថ្ងៃ២០ ខែមេសា ដល់ ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥។

ចំណែកឯក្រសួង-ស្ថាប័នចំនួន១៥ ដែលត្រូវបានដាក់ឱ្យអនុវត្តថវិកាកម្មវិធីរួមមាន តុលាការកំពូល, សាលាឧទ្ធរណ៍ អគ្គលេខាធិការដ្ឋានរដ្ឋសភា, អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, អាជ្ញាធរសវនកម្មជាតិ, អង្គភាពប្រឆាំងអំពើពុករលួយ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងធនធានទឹកនិងឧតុ និយម, ក្រសួងព័ត៌មាន, ក្រសួងបរិស្ថាន, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។ ក្នុងចំណោមក្រសួង-ស្ថាប័ន ទាំង១៥ មានក្រសួងចំនួន០៧ ដែលមានមន្ទីរជំនាញនៅរាជធានី-ខេត្ត រួមមាន ក្រសួងទេសចរណ៍, ក្រសួងពាណិជ្ជកម្ម, ក្រសួងធនធានទឹកនិងឧតុនិយម, ក្រសួងព័ត៌មាន, ក្រសួងបរិស្ថាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បណ្តុះបណ្តាលដល់ក្រុមលទ្ធកម្មដល់មន្ទីរជំនាញទាំងនោះនិងបានអញ្ជើញមន្ត្រី០២រូបក្នុង១មន្ទីរជំនាញក្នុងមួយរាជធានី-ខេត្ត ចូលរួមវគ្គបណ្តុះបណ្តាលចំនួនពីរវគ្គ÷

- វគ្គទី០១ ប្រព្រឹត្តទៅនៅថ្ងៃទី០៤-០៧ ខែមេសា ឆ្នាំ ២០១៦ មានសិក្ខាកាមចូលរួមចំនួន២០០នាក់
- វគ្គទី០២ប្រព្រឹត្តទៅនៅថ្ងៃទី២៥-២៨ខែមេសាឆ្នាំ២០១៦មានសិក្ខាកាមចូលរួមចំនួន១៥០ នាក់

ទន្ទឹមនេះបញ្ហាប្រឈមដែលនាំឱ្យស្ទូចនាករនៃសកម្មភាពទាំងនេះមិនសម្រេចបានតាមគោលដៅនៃត្រីមាសទី១ គឺបណ្តាលមកពីភាពមមាញឹក និងកង្វះពេលវេលាសម្រាប់អនុវត្ត។

ជាសេចក្តីសន្និដ្ឋានរួម វឌ្ឍនភាពប្រចាំត្រីមាសទី១ មិនទាន់សម្រេចបានតាមគោលដៅដែលចង់បាននៅឡើយ ប៉ុន្តែការពង្រឹងតម្លាភាពនៃកិច្ចលទ្ធកម្មសាធារណៈ គឺ តាមរយៈការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត, សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ, ផែនការលទ្ធកម្មសាធារណៈ និងការប្រគល់កិច្ចសន្យាគឺត្រូវបានបង្ហោះលើគេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។ ជាមួយគ្នានេះ ដើម្បីពង្រឹងការអនុវត្តលទ្ធកម្មសាធារណៈសម្រាប់គាំទ្រការអនុវត្តថវិកាកម្មវិធីរបស់ក្រសួង ស្ថាប័នឱ្យមានប្រសិទ្ធភាព អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈបាននិងកំពុងបណ្តុះបណ្តាល និងផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តដល់អង្គភាពលទ្ធកម្មថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋានសម្រាប់ក្រសួង-ស្ថាប័នទាំង២៥។

ផ្នែកទី១ ភាពជឿទុកចិត្តបាននៃថវិកា គឺនៅតែរក្សាបានជាសារវន្ត ដោយគ្មានបំណុលលើផ្នែកចំណាយបើទោះបីការកំណត់រយៈពេលមក៦០ថ្ងៃក៏ដោយ រីឯអង្គភាពប្រមូលចំណូលបាននិងកំពុងចាត់វិធានការគ្រប់គ្រងបំណុលតាមរយៈការពង្រឹងសមត្ថភាពសវនកម្មផ្ទៃក្នុងរបស់ពន្ធដារ និងការគ្រប់គ្រងបំណុលរបស់គយនិងរដ្ឋាករកម្ពុជាជាពិសេសការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ទោះបីជាយ៉ាងណាក៏ដោយ ទាំងក្រសួង-ស្ថាប័នអនុវត្តថវិកាកម្មវិធី និងមិនមែនថវិកាកម្មវិធីត្រូវពង្រឹងប្រសិទ្ធភាពការរៀបចំកម្មវិធីចំណាយ និងការអនុវត្តទៅតាមផែនការ ដើម្បីសម្រេចឱ្យបាននូវផែនការយុទ្ធសាស្ត្រថវិកា និងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។

## ២. គណនេយ្យភាពហិរញ្ញវត្ថុ

**ផ្នែកទី២÷ គណនេយ្យភាពហិរញ្ញវត្ថុ** ត្រូវបានគាំទ្រដោយគោលបំណងសំខាន់ៗចំនួន៤ ក្នុងនោះមាន ៤ ចង្កោមសកម្មភាព ដែលត្រូវបន្តពង្រឹង កែលម្អ និងពង្រីកការអនុវត្តនៅក្នុងដំណាក់កាលទី៣ ដើម្បីសម្រេចបានគណនេយ្យហិរញ្ញវត្ថុពេញលេញរួមមាន÷ (១) ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនីថ្មី, (២) ពង្រឹង និងពង្រីកការអនុវត្តប្រព័ន្ធអនុវត្តថវិកា និងដំណើរការប្រតិបត្តិការថ្មីដែលផ្តោតសំខាន់លើការអនុវត្តប្រព័ន្ធ FMIS

ដំណាក់កាលទី១ ឱ្យបានពេញលេញ និងពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ទៅដល់គ្រប់ក្រសួង ស្ថាប័ន (៣) ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព (៤)ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការ ដើម្បីបង្កើនការទទួលខុសត្រូវ និង គណនេយ្យភាព។

ក្នុងត្រីមាសទី១ នេះ មានសកម្មភាពគ្រោងអនុវត្ត ដោយអគ្គនាយកដ្ឋានចំនួន ០៥ រួមមាន អគ្គលេខាធិការ កសហវ, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គនាយដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ។

**២.១. ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនីថ្មី**

គោលបំណងនេះ សម្រេចបាន ៦២% ដោយមានតែ ១ ចង្កោមសកម្មភាព ២១.១ បន្តកែលម្អប្លង់គណនីថ្មី និងចំណាត់ថ្នាក់ថវិកាថ្មី (ភូមិសាស្ត្រ, អង្គភាពប្រតិបត្តិនិងរដ្ឋបាល, កម្មវិធី និង សេដ្ឋកិច្ច) និងអនុវត្តចំណាត់ថ្នាក់បីបន្ថែមទៀត (មុខងារ, មូលនិធិ និងគម្រោង) ដែលសម្រេចបាន ៦២%។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃចង្កោមសកម្មភាព ឃើញថា ក្នុងគោលបំណងនេះ មានសូចនាករសំខាន់ៗ ចំនួន ០១ សម្រេចបាន រួមមាន÷

១. ឧបសម្ព័ន្ធនៃចំណាត់ថ្នាក់អង្គភាពប្រតិបត្តិ និងរដ្ឋបាល ត្រូវបានរៀបចំលើកទី១។

ដោយឡែក សូចនាករសំខាន់ៗ ចំនួន ០៤ សម្រេចមិនបានពេញលេញតាមគោលដៅ រួមមាន÷

១. គណនីប្រាក់បញ្ញើរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលជាប្រាក់ដុល្លារនិងជាប្រាក់រៀល ត្រូវបានបើក (សម្រេចបាន ៣០%)។

២. គណនីប្រាក់បញ្ញើរបស់ គណនីពិសេស (440) បានបង្កើត (សម្រេចបាន ៩០%)។

៣. គណនីប្រាក់បញ្ញើរបស់គណនីពិសេស នៅរតនាគារ (120...) បានបង្កើត (សម្រេចបាន ៩០%)។

៤. ប្រកាសស្តីពីការកែសម្រួល COA សម្រាប់ប្រព័ន្ធ FMIS ត្រូវបានបង្កើតឱ្យស្របតាមកែសម្រួលប្លង់គណនីស្របតាម FMIS (សម្រេចបាន ៥០%)។

ជាសន្និដ្ឋានរួម ឃើញថាការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនីថ្មី ត្រូវបានបន្តពង្រឹងជាបណ្តើរៗ នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៦ នេះ។ ទោះបីជាយ៉ាងណា ការអនុវត្តនៅមិនទាន់មានភាពរលូននៅឡើយទេ ដោយសារតែទំហំការងារ និងបញ្ហាពេលវេលា។ លទ្ធផលនេះ ឆ្លុះបញ្ចាំងឱ្យឃើញពីភាពចាំបាច់របស់អគ្គនាយកដ្ឋានពាក់ព័ន្ធ ក្នុងការខិតខំបន្ថែមទៀត ដើម្បីសម្រេចការងារតាមផែនការដែលគ្រោងទុក។

**២.២. ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មី**

គោលបំណងនេះ មាន ០៥ ចង្កោមសកម្មភាព។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៦៣% ក្នុងនោះចង្កោមសកម្មភាព ២២.១ បន្តកាត់បន្ថយពេលវេលា សម្រាប់សំណើសុំធានាចំណាយ និងការទូទាត់ នៅតាមក្រសួង ស្ថាប័ន សម្រេចបាន ១០០%។ ចង្កោមសកម្មភាព ២២.២ កែលម្អប្រតិបត្តិការនៅ ក្នុង កសហវ/ក្រសួង-ស្ថាប័ន ដើម្បីឱ្យស្របទៅនឹងការវិវឌ្ឍន៍នៃប្លង់គណនី និងបទដ្ឋានគណនេយ្យ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់គណនីធនាគារជាប្រចាំ សម្រេចបានតែ ២៥%។ ចង្កោមសកម្មភាព ២២.៣ បង្កើនកម្រិតយល់ដឹងភាពជាម្ចាស់ការចូលរួមនិងសមត្ថភាពផ្នែក FMIS ដល់កសហវ ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចបានតែ

៦៣%។ ចង្កោមសកម្មភាព ២២.៤ កសាងសមត្ថភាពគ្រប់គ្រងគម្រោង FMIS ដោយរួមទាំងនៅកសហវ ក្រសួង- ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ សម្រេចបាន ៣០%។ ចង្កោមសកម្មភាព ២២.៥ អនុវត្តសាកល្បងជំហានដំបូង និង ពង្រីកការអនុវត្ត FMIS (ម៉ូឌុលស្នូល និងម៉ូឌុលសម្រាប់ថវិកានិងពង្រីកការអនុវត្តFMIS ទៅក្រសួងស្ថាប័ន) សម្រេច បាន ៧៣%។

ក្នុងគោលបំណងនេះ មានសូចនាករសំខាន់ៗ ចំនួន ០៥ សម្រេចបានតាមគោលដៅគឺ÷

១. យន្តការច្រកចេញចូលតែមួយត្រូវបានអនុម័ត ផ្សព្វផ្សាយ ណែនាំ និងដាក់ឱ្យអនុវត្ត ដោយបានបង្កើត ប្រកាសស្តីពីស្តង់ដារសេវាសាធារណៈរបស់កសហវ និងបានដាក់ឱ្យអនុវត្ត ដល់អង្គភាពថវិកានៃកសហវ។

២. ធានាការចូលរួមពេញលេញរបស់មន្ត្រីជំនាញថ្នាក់កណ្តាលនិងថ្នាក់រាជធានីខេត្ត ដោយអគ្គនាយកដ្ឋាន រតនាគារជាតិបានរៀបចំកិច្ចប្រជុំពិភាក្សា ជាមួយអ្នកផ្គត់ផ្គង់ប្រព័ន្ធ FMIS Contractor & នាយកដ្ឋានព័ត៌មានវិទ្យា (ITD)។ ប៉ុន្តែប្រព័ន្ធ FMIS នៅមានល្បឿនយឺតនិង Error (Budget Checking Errors)

៣. រតនាគាររាជធានីខេត្ត មានមន្ត្រីប្រមាណ១៥០រូបទទួលបានការបណ្តុះបណ្តាលលើការប្រើប្រាស់ប្រព័ន្ធ FMIS។

៤. ប្រព័ន្ធ FMIS ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៅគ្រប់អគ្គនាយកដ្ឋានពាក់ព័ន្ធទាំងអស់នៃ កសហវ និងនៅគ្រប់រតនាគាររាជធានី-ខេត្តតាមនីតិវិធីអនុវត្តការងារថ្មី។

៥. ទម្រង់អាណត្តិទូទាត់ចំណាយថ្មីឱ្យ ត្រូវបានបង្កើតស្របតាមតម្រូវការនៃការអនុវត្តថវិកាកម្មវិធី និង មាតិកា ថវិកាថ្មី ។

ដោយឡែក សូចនាករសំខាន់ៗ ចំនួន ០៣ សម្រេចមិនបានពេញលេញតាមគោលដៅ រួមមាន÷

១. សេចក្តីព្រាងឯកសារតម្រូវការផ្នែកបច្ចេកទេស និងមុខងារនៃប្រព័ន្ធ FMIS ជំហានទី២ ដំណាក់កាលទី១ (ការពង្រីកមុខងារទាំងអស់នៅជំហានទី១ ទៅក្រសួង-ស្ថាប័ន និង ថ្នាក់ក្រោមជាតិ) ត្រូវបានរៀបចំ (សម្រេចបាន ១០%)។

២. រចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធ FMIS មិនទាន់បានរៀបចំកែសម្រួល និង អនុម័តជាផ្លូវការជាមួយយន្តការ លើកទឹកចិត្តសមស្របជាលក្ខណៈប្រព័ន្ធ (សម្រេចបាន ៣០%)។

៣. សេចក្តីព្រាងឯកសារផែនការសកម្មពង្រីកការអនុវត្តប្រព័ន្ធ FMIS ជំហានទី២ ត្រូវបានរៀបចំរួចនៅខែ កុម្ភៈ ឆ្នាំ២០១៦ (សម្រេចបាន ៨០%)។

៤. ផែនការកសាងសមត្ថភាពមន្ត្រីគ្រប់គ្រងនិងអនុវត្តគម្រោង FMIS សម្រាប់បីឆ្នាំ (សម្រេចបាន ០%)។

ជាសន្និដ្ឋានរួម ការអនុវត្តប្រព័ន្ធអនុវត្តថវិកា និងដំណើរការប្រតិបត្តិការថ្មីដែលផ្តោតសំខាន់លើការអនុវត្ត ប្រព័ន្ធ FMIS ដំណាក់កាលទី១ ឱ្យបានពេញលេញ និងពង្រីកការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ ទៅ ដល់គ្រប់ក្រសួងស្ថាប័ន ត្រូវបានពង្រឹង និងពង្រីកជាបណ្តើរៗ នៅត្រីមាសទី១ នេះ។ ទន្ទឹមនឹងនេះ ក្រុមការងារ គ្រប់គ្រងគម្រោង FMIS គួរតែពន្លឿនរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធ FMIS និងផែនការបណ្តុះបណ្តាលមន្ត្រីរបស់ ខ្លួនសម្រាប់រយៈ ៣ឆ្នាំ ដើម្បីគាំទ្រដល់ការអនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី១ ឱ្យបានពេញលេញ និងឈានទៅ ដំណាក់កាលទី២។

**២.៣. ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព**

គោលបំណងនេះ មាន ០៤ ចង្កោមសកម្មភាព។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះ សម្រេចបាន ៧៦% ក្នុងនោះចង្កោមសកម្មភាព ២៣.១ រៀបចំស្តង់ដារគណនេយ្យសាធារណៈស្របតាមស្តង់ដារ IPSAS និងដាក់ឱ្យអនុវត្តជាបណ្តើរៗតាមលំដាប់លំដោយ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការពង្រីកការប្រើប្រាស់ FMIS និងបង្កើតជម្រើសសម្រាប់ការអនុវត្តជាជំហានៗ ទៅរកការអនុវត្តគណនីបង្គរ សម្រេចបាន ៩០%។ ដោយឡែក សម្រាប់ចង្កោមសកម្មភាព ២៣.២ កែលម្អទម្រង់របាយការណ៍អនុវត្តថវិកាដែលត្រូវផ្ញើទៅគណៈរដ្ឋមន្ត្រី និង ស្ថាប័ននីតិប្បញ្ញត្តិ សម្រេចបាន ៦០%, ចង្កោមសកម្មភាព ២៣.៣ កែលម្អទម្រង់របាយការណ៍និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជន សម្រេចបាន ៧៥% និងចង្កោមសកម្មភាព ២៣.៤ ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ សម្រេចបាន ៧៨%។

ក្នុងគោលបំណងនេះ មានសូចនាករសំខាន់ៗ ចំនួន០៣ សម្រេចបានពេញលេញ តាមគោលដៅ រួមមាន÷

១. សារាចរណែនាំស្តីពីបញ្ជិកាគណនេយ្យរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ លេខ០១៨សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ត្រូវបានរៀបចំរួចរាល់។

២. សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាននិងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវបានដាក់ឆ្លងប្រជុំអន្តរអគ្គនាយកដ្ឋានផ្ទៃក្នុងកសហវ។

៣. សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធាននិងនីតិវិធីនៃការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវបានដាក់ឆ្លងប្រជុំអន្តរអគ្គនាយកដ្ឋានផ្ទៃក្នុងកសហវ។

ដោយឡែក សូចនាករសំខាន់ៗ ចំនួន ០២ សម្រេចមិនបានពេញលេញតាមគោលដៅ រួមមាន÷

១.បូកសរុបតួលេខដើម្បីដាក់បញ្ចូលសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំដាក់ជូនទីស្តីការគណៈរដ្ឋមន្ត្រី និងស្ថាប័ន និតិប្បញ្ញត្តិ (សម្រេចបាន ៦០%)។

២. ប្រព័ន្ធគ្រប់គ្រងទិន្នន័យបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពក្រោមឱវាទកសហវទាំងថ្នាក់ កណ្តាលនិងថ្នាក់មូលដ្ឋាន (ដំណាក់កាលទី២) ត្រូវបានបង្កើត (សម្រេចបាន ៨០%)។

ជាសន្និដ្ឋាន លទ្ធផលដែលសម្រេចបានទាំងនេះ បានរួមចំណែកក្នុងការពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធចាំបាច់ត្រូវបន្តអនុវត្តសកម្មភាពដែលបានគ្រោងទុកបន្តទៀត ឱ្យស្របទៅតាមផែនការដែលបានដាក់ចេញ។

**២.៤. ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព**

គោលបំណងនេះ មាន ០៤ចង្កោមសកម្មភាព។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះ សម្រេចបាន ៧០% ក្នុងនោះចង្កោមសកម្មភាព ២៤.១ បង្កើតឱ្យមានទណ្ឌកម្មរដ្ឋបាលសមស្រប ចំពោះកំហុសឆ្គង ឬការគ្រប់គ្រងធនធាន សាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព។ ទណ្ឌកម្មនេះត្រូវចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្ត និង ធ្វើការផ្សព្វផ្សាយ និងណែនាំឱ្យបានទូលំទូលាយ សម្រេចបាន ១០០% និងចង្កោមសកម្មភាព ២៤.៤ រៀបចំនិងដាក់ឱ្យអនុវត្តទម្រង់របាយការណ៍វឌ្ឍនភាពអនុវត្តថវិកាប្រចាំត្រីមាស ឆមាសនិងប្រចាំឆ្នាំ(ដោយរំលេចពីការរៀបចំថវិកា លទ្ធផលសម្រេចបាននិង ព្រមទាំងវិធានការដោះស្រាយ ពីក្រសួងស្ថាប័ន ទៅក្រសួងសេដ្ឋកិច្ចនិង

ហិរញ្ញវត្ថុ និងនៅផ្ទៃក្នុងក្រសួងនីមួយៗ) សម្រេចបាន ១០០%។ ចំណែកឯចង្កោមសកម្មភាព ២៤.២ ធ្វើបច្ចុប្បន្នភាពនិងផ្តល់សិទ្ធិអំណាចនិងទន់ភ្លន់ជាបន្តបន្ទាប់ជូនអង្គភាពថវិកា សម្រេចបាន 0% និងចង្កោមសកម្មភាព ២៤.៣ ត្រួតពិនិត្យឡើងវិញ លើការអនុវត្តសិទ្ធិអំណាចនិងភាពទន់ភ្លន់ដែលបានផ្តល់ជូន ដើម្បីធ្វើជាមូលដ្ឋានក្នុងការពង្រីកការផ្តល់សិទ្ធិអំណាច និងភាពទន់ភ្លន់ ពុំមានសកម្មភាពត្រូវសម្រេចនៅឆមាសទី១ នេះទេ។

ក្នុងគោលបំណងនេះ មានសូចនាករសំខាន់ៗ ចំនួន០២ សម្រេចបានពេញលេញ តាមគោលដៅ រួមមាន÷

១. ទម្រង់របាយការណ៍វឌ្ឍនភាពអនុវត្តថវិកា (របាយការណ៍ហិរញ្ញវត្ថុ) ប្រចាំត្រីមាស ត្រូវបានកែលម្អ។

២. ទម្រង់របាយការណ៍វឌ្ឍនភាពថវិកា ប្រចាំត្រីមាស និង/ ឬ ឆមាស និងប្រចាំ ឆ្នាំ (កម្មវិធីនិង មិនមែនកម្មវិធី) នៅថ្នាក់រដ្ឋបាលកណ្តាល ត្រូវបានរៀបដាក់ឱ្យអនុវត្ត។

ដោយឡែក សូចនាករសំខាន់ៗ ចំនួន ០១ សម្រេចមិនបានពេញលេញតាមគោលដៅ រួមមាន÷

១. ប្រកាសស្តីពីក្របខ័ណ្ឌសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អង្គភាពថវិកា ត្រូវបានរៀបចំ (សម្រេចបាន 0%)។

ជាសន្និដ្ឋាន លទ្ធផលដែលសម្រេចបានលើការកែទម្រង់របាយការណ៍វឌ្ឍនភាពអនុវត្តថវិកា បានឆ្លុះបញ្ចាំងឱ្យឃើញពី ការពង្រឹងជាបណ្តើរៗ នូវការអនុវត្តឧបករណ៍ និងយន្តការ ដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព។ ប៉ុន្តែអគ្គនាយកដ្ឋានពាក់ព័ន្ធគួរតែជួយពន្លឿនសកម្មភាពដែលបានដាក់ចេញ ឲ្យបានទាន់ពេលវេលា។

### ៣. ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

**ផ្នែកទី៣÷ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** ត្រូវបានគាំទ្រដោយគោលបំណងចំនួន៦ និងចង្កោមសកម្មភាពចំនួន២៣។ គោលបំណងទាំង៦ នេះ រួមមាន (១) ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី, (២) ការរៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា, (៣) ការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព (រវាងនីតិបញ្ញត្តិនិងនីតិប្រតិបត្តិ, រវាងកសហវ និងក្រសួង-ស្ថាប័ន និងនៅក្នុងក្រសួង-ស្ថាប័ន), (៤) ការពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ (ការរៀបចំគោលនយោបាយនិងផែនការចំណូលនិងចំណាយរយៈពេលមធ្យម), (៥) ការរៀបចំប្រព័ន្ធត្រួតពិនិត្យ និង (៦) ការពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ។

ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ នេះ មានសកម្មភាពគ្រោងអនុវត្ត ដោយអគ្គនាយកដ្ឋានចំនួន ០៦ រួមមាន អគ្គលេខាធិការ កសហវ, អគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង។

លទ្ធផលនៃការអនុវត្តក្នុងត្រីមាសទី១ ឆ្នាំ២០១៦ នេះមានដូចតទៅ÷

#### ៣.១. ការពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធី

គោលបំណងនេះ មាន ០៣ ចង្កោមសកម្មភាព។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៩៣% ដែលក្នុងនោះ ចង្កោមសកម្មភាព ៣១.១ ការពិនិត្យឡើងវិញនិងការកែលម្អការអនុវត្តថវិកាកម្មវិធីសម្រេចបាន ៨៣%, ចង្កោមសកម្មភាព ៣១.២ ការរៀបចំយុទ្ធសាស្ត្រដើម្បីពង្រីកថវិកាកម្មវិធី សម្រេចបាន ១០០%

និងចង្កោមសកម្មភាព ៣១.៣ ការអនុវត្តផែនការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពសម្រាប់ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធី សម្រេចបាន ១០០%។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃចង្កោមសកម្មភាពទាំង ០៣ ឃើញថា ក្នុងគោលបំណងនេះ មានសូចនាករសំខាន់ៗ ចំនួន ០២ សម្រេចបាន រួមមាន÷

១. យុទ្ធសាស្ត្រដើម្បីពង្រីកថវិកាកម្មវិធីត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។

២. សៀវភៅគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី ត្រូវបានបោះពុម្ពចំនួន ១២០០ ច្បាប់។

៣. មន្ត្រីក្រសួង-ស្ថាប័នទាំង ១១ និងមន្ទីរជំនាញ ដែលនឹងអនុវត្តថវិកាកម្មវិធីនាឆ្នាំ២០១៧ ទទួលបានការបណ្តុះបណ្តាល។

ដោយឡែកសូចនាករសំខាន់ៗ ចំនួន ០២ សម្រេចមិនបានពេញលេញតាមគោលដៅ រួមមាន÷

១. សារាចរស្តីពីវិធីសាស្ត្រនៃការចរចាគម្រោងថវិកាកម្មវិធីប្រចាំរបស់ កសហវ ត្រូវបានរៀបចំ (អនុវត្តដោយអគ្គលេខាធិការដ្ឋាន កសហវ)។ សកម្មភាពនេះ នឹងអនុវត្តបន្តនៅត្រីមាសទី២ ជាបន្តទៀត ដោយស្នើសុំឱ្យមានការសហការពីអគ្គនាយកដ្ឋានថវិកា ដើម្បីសម្រេចឱ្យបានតាមពេលវេលាកំណត់។

២. ការបណ្តុះបណ្តាលស្តីពីគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ដល់ក្រសួង-ស្ថាប័នថ្មី ចំនួន ១៥ ត្រូវបានរៀបចំ។

ជាសន្និដ្ឋានរួម ឃើញថា ការអនុវត្តថវិកាកម្មវិធី ត្រូវបានបន្តពង្រឹង និងពង្រីក ជាបណ្តើរៗ នៅក្នុងត្រីមាសទី១ ឆ្នាំ២០១៦ នេះ។ ទោះបីជាយ៉ាងណា ការអនុវត្តនៅមិនទាន់មានភាពរលូននៅឡើយទេ ដោយសារតែទំហំការងារ និងបញ្ហាពេលវេលា។ លទ្ធផលនេះ ឆ្លុះបញ្ចាំងឱ្យឃើញពីភាពចាំបាច់របស់អគ្គនាយកដ្ឋានពាក់ព័ន្ធ ក្នុងការខិតខំបន្ថែមទៀត ដើម្បីសម្រេចការងារតាមផែនការដែលគ្រោងទុក។ ជាពិសេស ដើម្បីឆ្លើយតបទៅនឹងការអនុវត្តថវិកាកម្មវិធីពេញលេញ របស់ក្រសួង-ស្ថាប័នទាំង១៥ អគ្គនាយកដ្ឋានពាក់ព័ន្ធត្រូវពង្រឹងការផ្តល់ជំនួយបច្ចេកទេស និងបណ្តុះបណ្តាលបន្ថែមដល់ក្រសួង-ស្ថាប័ន ដែលត្រូវអនុវត្តថវិកាកម្មវិធីពេញលេញ ក្នុងឆ្នាំ២០១៦ នេះ។

### ៣.២. ការរៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណកម្មថវិកា

គោលបំណងនេះ មាន ០២ ចង្កោមសកម្មភាព។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះ សម្រេចបាន ១០០% ពេញលេញតាមគោលដៅ ក្នុងនោះចង្កោមសកម្មភាព ៣២.១ បន្តកែលម្អការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន តាមរយៈក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF), ផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាកម្មវិធី (PB) សម្រេចបាន ១០០%។ ដោយឡែក ចង្កោមសកម្មភាព ៣២.២ ការបញ្ចូលចំណូល-ចំណាយដែលនៅក្រៅបរិបទថវិកាទៅក្នុងថវិកាប្រចាំឆ្នាំ ដោយរួមទាំងថវិកាដៃគូអភិវឌ្ឍន៍ មិនមានសកម្មភាពគ្រោងអនុវត្តក្នុងត្រីមាសទី ១ នេះទេ។

ក្នុងគោលបំណងនេះ មានសូចនាករសំខាន់ៗ ចំនួន ០៤ សម្រេចបានតាមគោលដៅគឺ÷

១. គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រចាំឆ្នាំ ត្រូវបានត្រួតពិនិត្យ និងធ្វើការកែលម្អឱ្យស្របតាមការអនុវត្ត។

២. តារាងឧបសម្ព័ន្ធនៃគោលការណ៍ណែនាំត្រូវបានធ្វើបច្ចុប្បន្នភាព។

៣. ការបណ្តុះបណ្តាល និងជំនួយបច្ចេកទេស ត្រូវបានផ្តល់ជូនក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងដែនដីនគរូបនីយកម្មនិងសំណង់ និងក្រសួងបរិស្ថាន។

៤. ក្របខណ្ឌចំណាយវិនិយោគ និងចំណាយជួសជុលថែទាំ ត្រូវបានបញ្ចូលទៅក្នុងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចឆ្នាំ ២០១៧-២០១៩។

គួរបញ្ជាក់ផងដែរថា សកម្មភាព ៣២.៦.២ ការធ្វើប្រតិភូកម្មអំណាចបន្ថែមដល់ក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុក្នុងការចុះទិដ្ឋាការលើលិខិតធានាចំណាយ និងអាណត្តិបើកប្រាក់ ដែលជាសកម្មភាពត្រូវសម្រេចក្នុងឆ្នាំ២០១៥ (CAP2-New) ត្រូវបានសម្រេចពេញលេញ ១០០% ហើយ ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ នេះ តាមរយៈការដាក់ឱ្យប្រើប្រាស់ប្រកាសលេខ ២៧៤ សហវ.ហក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពី ការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុអមផ្ទាល់តាមក្រសួង-ស្ថាប័ន នៅរដ្ឋបាលកណ្តាលក្នុងការពិនិត្យសម្រេចផ្តល់ទិដ្ឋាការលើលិខិតធានាចំណាយនិងលើអាណត្តិបើកប្រាក់។ បើទោះបីជា មានការយឺតយ៉ាវ ប៉ុន្តែប្រកាសនេះត្រូវបានដាក់ចេញឱ្យអនុវត្តទាន់ពេលវេលា។

ជាសេចក្តីសន្និដ្ឋានរួម សកម្មភាព និងសូចនាករដែលបានកំណត់ក្នុងត្រីមាសទី០១ ឆ្នាំ២០១៦ នៃផែនការសកម្មភាពដំណាក់កាលទី០៣ នេះ ត្រូវបានសម្រេចតាមការគ្រោងទុក ដែលលទ្ធផលនេះ មានភាពចាំបាច់សម្រាប់ការរៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងការធ្វើសមាហរណកម្មថវិកា។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានជំនាញពាក់ព័ន្ធ ត្រូវបន្តបណ្តុះបណ្តាល និងផ្តល់ជំនួយបច្ចេកទេស ដល់ក្រសួង-ស្ថាប័នបន្ថែមទៀត តាមការស្នើសុំ។

**៣.៣. ការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព**

គោលបំណងនេះ មាន ០៤ ចង្កោមសកម្មភាព។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ១០០% ពេញលេញតាមគោលដៅ ក្នុងនោះចង្កោមសកម្មភាព ៣៣.១ ការពិនិត្យឡើងវិញ និងរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល ក្នុងបរិបថនៃការអនុវត្តថវិកាកម្មវិធី សម្រេចបាន ១០០% និងចង្កោមសកម្មភាព ៣៣.៤ ការកែសម្រួលរចនាសម្ព័ន្ធស្ថាប័ន ឱ្យឆ្លើយតបទៅនឹងប្រព័ន្ធដំណើរការការងារថ្មីដែលត្រូវបានបង្កើត សម្រេចបាន ១០០%។ ដោយឡែក សម្រាប់ចង្កោមសកម្មភាព ៣៣.២ និងចង្កោមសកម្មភាព ៣៣.៣ មិនមានសកម្មភាពគ្រោងអនុវត្តដោយអគ្គនាយកដ្ឋានក្នុងត្រីមាសទី១ នេះទេ។

ក្នុងគោលបំណងនេះ មានសូចនាករសំខាន់ៗ ចំនួន ០២ សម្រេចបានពេញលេញ តាមគោលដៅ រួមមាន÷

១. ប្រកាសលេខ ២៧៤ សហវ.ហក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពី ការប្រគល់សិទ្ធិជាអភិបាលហិរញ្ញវត្ថុអមផ្ទាល់តាមក្រសួង-ស្ថាប័នរដ្ឋបាលកណ្តាល ក្នុងការពិនិត្យសម្រេចផ្តល់ទិដ្ឋាការលើលិខិតធានាចំណាយនិងលើអាណត្តិបើកប្រាក់។

២. ប្រកាសលេខ ៣៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ ស្តីពី នីតិវិធីនិងបែបបទចំណាយថវិកាអន្តរាគមន៍ជួសជុលបន្ទាន់ ក្រោមសមត្ថកិច្ចក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវបានរៀបចំ។

ជាសេចក្តីសន្និដ្ឋាន លទ្ធផលដែលសម្រេចបានទាំងនេះ បានឆ្លុះបញ្ចាំងឱ្យឃើញពីលទ្ធភាពក្នុងការរៀបចំនិងការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាពប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋាន

ជំនាញពាក់ព័ន្ធចាំបាច់ត្រូវបន្តអនុវត្តសកម្មភាពដែលបានគ្រោងទុកបន្តទៀត ឱ្យស្របទៅតាមផែនការដែលបានដាក់ចេញ។

### ៣.៤. ការពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ

គោលបំណងនេះ មាន ៣ ចង្កោមសកម្មភាព។ បើផ្អែកលើសកម្មភាពដែលបានដាក់ចេញ គោលបំណងនេះ សម្រេចបាន ៥៨% ក្នុងនោះ ចង្កោមសកម្មភាព៣៤.១.ពង្រឹងសមត្ថភាពរៀបចំនិងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌ គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច សម្រេចបាន ១០០%, ចង្កោមសកម្មភាព៣៤.២.ពង្រឹងសមត្ថភាពរៀបចំនិងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌចំណូល-ចំណាយរយៈពេលមធ្យម មិនសម្រេចបាន និងចង្កោមសកម្មភាព៣៤.៣. ពង្រឹង សមត្ថភាពវិភាគ និងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រេចបាន ៩៤%។

ដោយឡែក បើពិនិត្យមើលលទ្ធផលសម្រេចបាននៃចង្កោមសកម្មភាពទាំង៣ ឃើញថា មានសូចនាករ ៣ សម្រេចបានតាមគោលដៅ គឺ÷

១. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ត្រូវបានរៀបចំ

២. ម៉ូដែលម៉ាក្រូសេដ្ឋកិច្ច ត្រូវបានធ្វើតេស្តសាកល្បង តាមគំរូ IMF និងមានរបាយការណ៍

៣. ឯកសារទស្សនទានស្តីពីការពិនិត្យឡើងវិញនូវគោលនយោបាយសារពើពន្ធ ត្រូវបានរៀបចំរួចរាល់

ដោយឡែក មានសូចនាករចំនួន ២ ដែលមិនសម្រេចតាមគោលដៅ គឺ÷

១. ឯកសារទស្សនទាន ក្នុងការរៀបចំ MTEF ដើម្បីបង្កើនប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពក្នុងការរៀបចំថវិកា ត្រូវបានរៀបចំ

២. ទស្សនកិច្ចសិក្សា ស្តីពីហិរញ្ញប្បទានសម្រាប់ការបណ្តុះបណ្តាលជំនាញ ត្រូវបានរៀបចំ

ជាសេចក្តីសន្និដ្ឋានរួមឃើញថា ការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ (ការរៀបចំគោលនយោបាយនិង ផែនការចំណូលនិងចំណាយរយៈពេលមធ្យម ត្រូវបានពង្រឹង គិតត្រឹមត្រីមាសទី១ ឆ្នាំ ២០១៦ ទោះបីជាការអនុវត្តនៅមិនទាន់មានភាពរលូន និងជួបប្រទះបញ្ហាប្រឈមមួយចំនួនក៏ដោយ។ លទ្ធផលនេះ បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ ដែលត្រូវខិតខំបន្ថែមទៀត ជាពិសេស ដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើង និងត្រូវពង្រឹងការរៀបចំ MTEF ដើម្បីបន្សុីគ្នារវាងគោលនយោបាយជាតិនានា និងផែនការយុទ្ធសាស្រ្តថវិការបស់ក្រសួង។

### ៣.៥. ការរៀបចំប្រព័ន្ធត្រួតពិនិត្យ

គោលបំណងនេះ មានចង្កោមសកម្មភាពចំនួន៥។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន៨៧% ក្នុងនោះ ចង្កោមសកម្មភាព ៣៥.១ ត្រួតពិនិត្យមើលឡើងវិញពីប្រព័ន្ធត្រួតពិនិត្យ អធិការកិច្ច សវនកម្ម និងសវនកម្មផ្ទៃក្នុងនាពេលបច្ចុប្បន្ននៅគ្រប់ក្រសួង-ស្ថាប័ន សម្រេចបាន១០០%, ចង្កោមសកម្មភាព ៣៥.២ រៀបចំប្រព័ន្ធត្រួតពិនិត្យថ្មីឱ្យមាន ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងឆ្លើយតបបានទៅនឹង បរិបទថ្មី ដើម្បីបំពេញមុខងារគ្នាទៅ វិញទៅមកសម្រាប់ការគ្រប់គ្រងគ្រប់ក្រសួង ស្ថាប័ន សម្រេចបាន ៨២%, ចង្កោមសកម្មភាព ៣៥.៣ កែលម្អយន្តការត្រួតពិនិត្យ ដើម្បីធានាការឆ្លើយតបក្នុងការបំពេញមុខងាររវាងសវនកម្មផ្ទៃក្នុង និងអធិការកិច្ចប្រកប

ដោយប្រសិទ្ធភាពទៅនឹងលទ្ធផលដែលរកឃើញដោយសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចសម្រេចបាន ៦០%, ចង្កោមសកម្មភាព ៣៥.៤ រៀបចំនិងកែលម្អ ផែនការសកម្មភាព និងកម្មវិធីសវនកម្ម/អធិការកិច្ច ប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ និង ចាត់វិធានការវាយតម្លៃហានិភ័យ ដែលផ្តល់អនុសាសន៍ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចបាន ៩០%។ ដោយឡែក ចង្កោមសកម្មភាព ៣៥.៥ មិនមានផែនការអនុវត្តដែលគ្រោងដោយអគ្គនាយកដ្ឋានពាក់ព័ន្ធ។

ដោយឡែក បើពិនិត្យមើលលទ្ធផលសម្រេចបាននៃចង្កោមសកម្មភាពទាំង៤ ឃើញថា មានសូចនាករ ០៤ សម្រេចបានតាមគោលដៅ គឺ៖

១. នីតិវិធីនៃការរៀបចំឯកសារដំណើរការ និងការបង្កើតអនុស្សារណៈសវនកម្ម (ឧបសម្ព័ន្ធភ្ជាប់នៅ GDIA) ត្រូវបានរៀបចំ

២. សេចក្តីព្រាងរចនាសម្ព័ន្ធថ្មី Box cloud នៃ Database ត្រូវបានរៀបចំ

៣. ដំណើរការប៉ាន់ប្រមាណអំពីតម្រូវការវគ្គបណ្តុះបណ្តាលបច្ចេកទេស ជំនាញការងារអធិការកិច្ចហិរញ្ញវត្ថុត្រូវបានរៀបចំ

៤. ផែនការ និងរបាយការណ៍សវនកម្មរបស់ក្រសួងស្ថាប័ន ត្រូវបានពិនិត្យ និងផ្តល់យោបល់។ ក្នុងនោះ មានចំនួន ៤ គោលដៅ៖ (១) ផ្តល់យោបល់លើរបាយការណ៍សវនកម្មរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (ពិនិត្យតារាងផ្នែកគុណភាពរបាយការណ៍) (២) ផ្តល់យោបល់បន្ថែមលើផែនការសវនកម្មឆ្នាំ ២០១៦ របស់ប្រៃសណីយ៍កម្ពុជា (ពិនិត្យតារាងផ្នែកផែនការសវនកម្ម) (៣) ផែនការរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(ពិនិត្យតារាងផ្នែកផែនការសវនកម្ម) (៤) របាយការណ៍សវនកម្មរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវបានពិនិត្យនិងផ្តល់យោបល់កែលម្អ ។

ដោយឡែក មានសូចនាករចំនួន ២ ដែលមិនសម្រេចតាមគោលដៅ គឺ៖

១. ផែនការតម្រូវការមតិប្រឹក្សាច្បាប់បីឆ្នាំរំកិលលើលិខិតបទដ្ឋានគតិយុត្ត សម្រាប់រៀបចំនូវ ប្រព័ន្ធត្រួតពិនិត្យថ្មីដែលមានស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងឆ្លើយតបបាន ទៅនឹងបរិបទថ្មី ដើម្បីបំពេញមុខងារគ្នាទៅវិញទៅមក សម្រាប់ការគ្រប់គ្រងគ្រប់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ។ សកម្មភាពនេះត្រូវបានពន្យារពេលដោយសារការងារអាទិភាពជាច្រើនផ្សេងទៀត។

២. ផែនការមតិប្រឹក្សាច្បាប់បីឆ្នាំរំកិលលើការកែលម្អយន្តការត្រួតពិនិត្យ ដើម្បីធានាការឆ្លើយតបក្នុងការបំពេញមុខងាររវាងសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចប្រកបដោយប្រសិទ្ធភាព ទៅនឹងលទ្ធផលដែលរកឃើញដោយសវនកម្មផ្ទៃក្នុងនិងអធិការកិច្ចគ្រប់គ្រងគ្រប់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំ។ សកម្មភាពនេះ ត្រូវបានពន្យារពេលដោយសារការងារអាទិភាពជាច្រើនផ្សេងទៀត។

ជាសេចក្តីសន្និដ្ឋានរួមឃើញថា ការរៀបចំប្រព័ន្ធត្រួតពិនិត្យនៃសវនកម្មផ្ទៃក្នុង និងនីតិវិធីនៃការតាមដានអនុវត្តអនុសាសន៍សវនកម្ម (Audit Follow-up) ដំណើរការបានដោយរលូន និងឆ្លើយតបបានទៅនឹងបរិបទថ្មី ដើម្បីបំពេញមុខងារគ្នាទៅវិញទៅ មកសម្រាប់ការគ្រប់គ្រង ក្នុងផែនការសកម្មភាពដំណាក់កាលទី៣ នេះ ត្បិតការអនុវត្តនៅមិនទាន់មានភាពរលូន និងចង្កោមសកម្មភាពមួយចំនួនមិនទាន់បានរៀបចំនៅឡើយ និងត្រូវបានពន្យាពេលអនុវត្ត

នៅត្រីមាសបន្ទាប់។ លទ្ធផលនេះ បានសបញ្ជាក់យ៉ាងច្បាស់ពីការខិតខំប្រឹងប្រែងឱ្យខានតែបាន ក្នុងការពង្រឹងប្រព័ន្ធត្រួតពិនិត្យ ដើម្បីឈានឆ្ពោះទៅរកប្រព័ន្ធ បទដ្ឋានរួម និងឆ្លើយតបដំណើរវិវត្តន៍របស់ប្រព័ន្ធការងារថ្មី។

**៣.៦. ការពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ**

គោលបំណងនេះ មានចង្កោមសកម្មភាពចំនួន៦។ បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះ សម្រេចបាន៨០% ក្នុងនោះ ចង្កោមសកម្មភាព ៣៦.១. ពិនិត្យមើលឡើងវិញ និងអនុវត្តគោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុរយៈពេលមធ្យម និងវែង សម្រេចបាន ៦៥%, ចង្កោមសកម្មភាព ៣៦.២ អនុវត្តការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចបាន ១០០%, ចង្កោមសកម្មភាព ៣៦.៣. អនុវត្តសាកល្បងនិងពង្រីកមូលនិធិវិនិ យោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNIF) សម្រេចបាន ៥០%, ចង្កោមសកម្មភាព ៣៦.៤. ពិនិត្យមើលឡើងវិញ និង ដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចបាន ១០០%, ចង្កោមសកម្មភាព ៣៦.៥. រៀបចំនិងអនុវត្តការផ្ទេរធនធានមានភ្ជាបលក្ខខណ្ឌ សម្រេចបាន ៨០%, ចង្កោមសកម្មភាព ៣៦.៦. រៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំនិងការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាសម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ សម្រេចបាន ៨០%។

បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករចង្កោមសកម្មភាពសម្រាប់ត្រីមាសទី១ ឆ្នាំ ២០១៦ នេះ ឃើញថា មាន សូចនាករចំនួន ៦ សម្រេចបានតាមគោលដៅ គឺ÷

១. សេចក្តីព្រាងឯកសារគោល នយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុ រយៈពេលមធ្យម និងវែងត្រូវបាន ពិនិត្យនិងកែលំអ

២. អនុក្រឹត្យស្តីពីការរៀបចំប្រាក់ឧបត្ថម្ភសមាជិកក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៦ ត្រូវបានរៀបចំរួច និងដាក់ឱ្យប្រើប្រាស់

៣. គោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបាន ពិនិត្យកែសម្រួល និងដាក់ឱ្យអនុវត្ត

៤. បន្តកែលំអសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

៥. សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ ស្តីពីការផ្ទេរធនធានមានភ្ជាប់លក្ខខណ្ឌត្រូវបានរៀបចំរួច

៦. គោលការណ៍សម្រាប់រៀបចំថវិកាកម្មវិធី សម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំរួច

ដោយឡែក មានសូចនាករចំនួន ៣ ដែលមិនសម្រេចតាមគោលដៅ គឺ÷

១. គោលការណ៍សម្រាប់អនុវត្តថវិកាកម្មវិធី ត្រូវបានរៀបចំ

២. ក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានបង្កើត។ ការខកខានក្នុងការបង្កើតក្រុមប្រឹក្សាភិបាលគ្រប់គ្រងមូលនិធិវិនិយោគរដ្ឋបាលថ្នាក់ក្រោមជាតិ គឺដោយសារក្រសួង-ស្ថាប័នមួយចំនួនមិនទាន់បញ្ជូនសមាសភាពមក គសហវ

៣. សេចក្តីព្រាងលិខិតបទដ្ឋាន គតិយុត្តិស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ត្រូវបានរៀបចំ។ បច្ចុប្បន្នសេចក្តីព្រាងសម្រេចបាន ៣០%។

ទន្ទឹមនឹងនេះ មានសកម្មភាពមួយត្រូវបានស្នើសុំពន្យារទៅអនុវត្តនៅត្រីមាសទី២វិញ គឺសកម្មភាព ៣៦.៦.៧ ផែនការតម្រូវការមតិប្រឹក្សាច្បាប់បីឆ្នាំរំកិល លើលិខិតបទដ្ឋានគតិយុត្ត សម្រាប់រៀបចំនីតិវិធី និងគោលការណ៍សម្រាប់អនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកាសម្រាប់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវអនុវត្តដោយនាយកដ្ឋាននីតិកម្មនៃអគ្គលេខាធិការដ្ឋាន កសហវ។

ជាការសន្និដ្ឋាន ការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ត្រូវបានកំពុងបន្តពង្រឹង និងពង្រីកស្របតាមគោលដៅកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុដំណាក់កាលទី៣ បើទោះបីជាការអនុវត្តនៅមិនទាន់មានភាពរលូន និងចង្កោមសកម្មភាពមួយចំនួនមិនសម្រេចបានតាមគោលដៅក៏ដោយ។ លទ្ធផលនេះ បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ដែលត្រូវខិតខំបន្ថែមទៀត ជាពិសេស ត្រូវបញ្ចប់សកម្មភាពចំពោះសូចនាករដែលមិនសម្រេចបានតាមគោលដៅខាងលើ។

## ៤. ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់

ផ្នែកទី៤ ត្រូវបានបង្កើតឡើង សម្រាប់គាំត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ ដែលយើងចង់បានក្របខ័ណ្ឌថវិកាក្របខ័ណ្ឌគណនេយ្យ និងក្របខ័ណ្ឌសវនកម្មដោយផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ តាមរយៈគោលបំណងចំនួន ៤ រួមមាន (១) បង្កើតក្របខ័ណ្ឌថវិកាដោយផ្អែកលើសមិទ្ធកម្ម (២) បង្កើតក្របខណ្ឌគណនេយ្យភាពនៃសមិទ្ធិកម្ម (៣) បង្កើតក្របខណ្ឌសវនកម្មលើសមិទ្ធិកម្ម និង (៤) រៀបចំផែនការកសាងសមត្ថភាព (ដោយរួមទាំងស្ថាប័ននីតិប្បញ្ញត្តិ និង អាជ្ញាធរសវនកម្មជាតិ និង គោលបំណងដែលស្ថិតនៅក្រោមផ្នែកទី៤នេះ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពអនុវត្តចំនួន៩ ទៀត។ ប៉ុន្តែក្នុងផ្នែកទី៤នេះ ចង្កោមសកម្មភាពដែលពុំមានរៀបចំសកម្មភាពមានដូចជា÷

៤២.១. សិក្សានិងរៀបចំក្របខណ្ឌគោល នៃការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម (Performance Based Management- PBM) (អគ្គលេខាធិការដ្ឋាន)

៤២.២. ពិគ្រោះយោបល់លើគោលការណ៍គ្រប់គ្រងផ្អែកលើសមិទ្ធកម្ម (អគ្គលេខាធិការដ្ឋាន)

៤៣.២. ពិគ្រោះយោបល់លើគោលការណ៍សវនកម្មផ្អែកលើសមិទ្ធកម្ម (អគ្គលេខាធិការដ្ឋាន និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង)

៤៤.៣. ផ្សព្វផ្សាយ និងអនុវត្តផែនការកសាងសមត្ថភាព (អគ្គលេខាធិការដ្ឋាន)

បើផ្អែកលើការសម្រេចបាននៃគោលបំណងទាំង៤ នេះ ឃើញថា ផ្នែកនេះជារួមសម្រេចបាន ២០% ដោយក្នុងនោះ គោលបំណង៤១ សម្រេចបាន ៦០%, គោលបំណង ៤២ គ្មានសកម្មភាពគ្រោងអនុវត្ត, គោលបំណង៤៣ មិនទាន់ដល់ពេលអនុវត្ត និងគោលបំណង៤៤ សម្រេចបាន ១៨%។ ក្នុងនោះ យើងអាចសន្និដ្ឋានបានថា សម្រាប់គាំទ្រដល់ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ ស្ថិតនៅក្នុងកម្រិតមួយដែលពុំទាន់មានភាពសកម្មភាពខ្លាំងក្លា គ្រប់ជ្រុងជ្រោយដោយខ្វះការរៀបចំសកម្មភាព ការអនុវត្ត និងការប្តេជ្ញាចិត្តខ្ពស់ពីបណ្តាគ្រប់អគ្គនាយកដ្ឋានទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅឡើយ។

### ៤.១. បង្កើតក្របខ័ណ្ឌថវិកា ដោយផ្អែកលើសមិទ្ធកម្ម

គោលបំណងនេះ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន២ រួមមាន៤១.១.សិក្សានិងរៀបចំក្របខ័ណ្ឌគោលនៃ គោលការណ៍ថវិកាផ្អែកលើសមិទ្ធកម្ម (Performance Based Budgeting- PBB) ៤១.២.ពិគ្រោះ

យោបល់លើគោលការណ៍ថវិកាផ្អែកលើសមិទ្ធកម្ម។ បើពិនិត្យលើលទ្ធផលសម្រេចបាន គោលបំណងនេះអនុវត្តបានតែ៦០% ដោយក្នុងនោះ ចង្កោមសកម្មភាព៤១.១.សម្រេចបាន៦០% និង៤១.២.មិនទាន់ដល់ពេលអនុវត្ត។

ក្នុងនោះ ឃើញថាពុំមានសូចនាករណាមួយសម្រេចបានតាមគោលដៅនោះទេដូចជា÷

១. របាយការណ៍សិក្សាស្ដីពីក្របខ័ណ្ឌគោលនៃគោលការណ៍ថវិកាផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ និងរៀបចំ និងដាក់ឱ្យអនុវត្តយន្តការត្រួតពិនិត្យសមិទ្ធកម្មសាកល្បងសម្រាប់ថវិកាកម្មវិធីដោយផ្ដោតលើលទ្ធផល

២. គោលការណ៍ថវិកាផ្អែកលើសមិទ្ធកម្មត្រូវបានពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័ន និងអង្គភាពពាក់ព័ន្ធ

ក្នុងនោះ ឃើញថា អគ្គលេខាធិការដ្ឋានអត់បានរាយការណ៍វឌ្ឍនភាពនៃការអនុវត្តសកម្មភាពចំនួនមួយ បើទោះបីជាមានសកម្មភាពនៅក្នុងផែនការសកម្មភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក៏ដោយ។

ដូចនេះ យើងអាចសន្និដ្ឋានបានថា គោលបំណងទី១នេះ មិនទាន់បានអនុវត្តពេញលេញគ្រប់ជ្រុងជ្រោយនៅក្នុងត្រីមាសនេះនៅឡើយទេ។

### ៤.២. បង្កើតក្របខ័ណ្ឌគណនេយ្យភាពនៃសមិទ្ធកម្ម

គោលបំណងនេះ ត្រូវបានគាំទ្រដោយចង្កោមសក្មភាពចំនួន២ រួមមាន ៤២.១.សិក្សានិងរៀបចំក្របខណ្ឌគោល នៃការគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម (Performance Based Management- PBM) និង ៤២.២.ពិគ្រោះយោបល់លើគោលការណ៍គ្រប់គ្រងផ្អែកលើសមិទ្ធកម្ម។ គោលបំណងនេះមិនអាចវាស់វែងបានឡើយ ដោយពុំមានអគ្គនាយកដ្ឋានរៀបចំសកម្មភាពគាំទ្រចង្កោមសកម្មភាពឡើយ។

ដូចនេះ យើងអាចសន្និដ្ឋានបានថា គោលបំណងទី២ នេះ ក៏ស្ថិតនៅក្នុងកម្រិតមួយពុំទាន់ឆ្លើយតបបានទាំងស្រុងតាមទិសដៅដែលបានដាក់ចេញនៅឡើយដែលទាមទារឱ្យអគ្គនាយកដ្ឋាន ជាពិសេសអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុត្រូវរៀបចំសកម្មភាពដើម្បីគាំទ្រចង្កោមសកម្មភាពទាំងអស់នេះ។

### ៤.៣. បង្កើតក្របខ័ណ្ឌសវនកម្មលើសមិទ្ធកម្ម

គោលបំណងនេះ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន២ រួមមាន ៤៣.១.សិក្សានិងរៀបចំក្របខណ្ឌគោលនៃ សវនកម្មផ្អែកលើសមិទ្ធកម្ម (Performance Based Auditing- PBA) និង ៤៣.២. ពិគ្រោះយោបល់លើគោលការណ៍សវនកម្ម ផ្អែកលើសមិទ្ធកម្ម។ បើពិនិត្យលើលទ្ធផលសម្រេចបាន គោលបំណងនេះមិនអាចវាស់វែងបានទេដោយក្នុងនោះ ចង្កោមសកម្មភាព៤៣.១. មិនទាន់ដល់ពេលអនុវត្ត និង៤៣.២. ពុំមានអគ្គនាយកដ្ឋានរៀបចំសកម្មភាពគាំទ្រចង្កោមសកម្មភាព។

ដូចនេះ យើងអាចសន្និដ្ឋានបានថា គោលបំណងទី៣ នេះ ក៏ស្ថិតនៅក្នុងកម្រិតមួយពុំទាន់ឆ្លើយតបបានទាំងស្រុងតាមទិសដៅដែលបានដាក់ចេញនៅឡើយដែលទាមទារឱ្យអគ្គនាយកដ្ឋាន ជាពិសេសអគ្គលេខាធិការដ្ឋានក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងត្រូវរៀបចំសកម្មភាពដើម្បីគាំទ្រចង្កោមសកម្មភាពទាំងអស់នេះ។

### ៤.៤. រៀបចំផែនការកសាងសមត្ថភាព (ដោយរួមទាំង ស្ថាប័ន នីតិប្បញ្ញត្តិ និងអាជ្ញាធរសវនកម្មជាតិ)

គោលបំណងនេះ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន២ រួមមាន ៤៤.១.រៀបចំផែនការកសាងសមត្ថភាព (Capacity Development Plan-CDP) ៤៤.២. ពិគ្រោះយោបល់ និងអនុម័តផែនការកសាងសមត្ថភាព

និង៤៤.៣.ផ្សព្វផ្សាយ និងអនុវត្តផែនការកសាងសមត្ថភាព។ បើពិនិត្យលើលទ្ធផលសម្រេចបាន គោលបំណងនេះអនុវត្តបានតែ ១៨% ដោយក្នុងនោះ ចង្កោមសកម្មភាព ៤៤.១. សម្រេចបាន ៥៥%, ចង្កោមសកម្មភាព ៤៤.២. មិនបានរាយការណ៍ 0%, និងចង្កោមសកម្មភាព ៤៤.៣ ពុំមានអគ្គនាយកដ្ឋានរៀបចំសកម្មភាពគាំទ្រចង្កោមសកម្មភាព។

ក្នុងនោះ ឃើញថាពុំមានសូចនាករណាមួយសម្រេចបានតាមគោលដៅនោះទេ។ ប៉ុន្តែយើងអាចសង្កេតបានថា ផែនការកសាងសមត្ថភាពត្រូវបានរៀបចំដោយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានវឌ្ឍនភាពមួយចំនួន។

ដូចនេះ យើងអាចសន្និដ្ឋានបានថា គោលបំណងទី ៤ នេះ មិនទាន់បានអនុវត្តបានឡើយក្នុងត្រីមាសនេះ។ ម្យ៉ាងវិញទៀត អគ្គនាយកដ្ឋានមិនបានរាយការណ៍ និង មិនបានរៀបចំសកម្មភាពគាំទ្រនៅឡើយ។

## ៥. ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព

ផ្នែកទី៥ ត្រូវបានបង្កើតឡើង សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាពតាមរយៈគោលបំណងចំនួន៣ រួមមាន ៥១.បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន២, ៥២.បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន២ និង ៥៣. ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន៤។

បើផ្អែកលើការសម្រេចបាននៃគោលបំណងទាំង៣ នេះ ឃើញថា ផ្នែកនេះជារួមសម្រេចបាន៧១% ដោយក្នុងនោះ គោលបំណង៥១ សម្រេចបាន៥៦%, គោលបំណង៥២ សម្រេចបាន៧៩% និងគោលបំណង៥៣ សម្រេចបាន ៧៥%។ ក្នុងនោះ យើងអាចសន្និដ្ឋានបានថា សកម្មភាពសម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព ស្ថិតនៅក្នុងកម្រិតមួយដែលពុំទាន់មានភាពសកម្មភាពខ្លាំងក្លា និងការប្តេជ្ញាចិត្តខ្ពស់ពីបណ្តាគ្រប់អគ្គនាយកដ្ឋានទាំងអស់ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេស ការបង្កើនឆន្ទៈកំណែទម្រង់ ភាពជាម្ចាស់ ការទទួលខុសត្រូវ និងការពង្រឹងការកសាងសមត្ថភាព សម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ ហាក់នៅមានកម្រិតទាប និងស្ថិតនៅក្នុងក្តីបារម្ភ និងពុំទាន់ឆ្លើយតបបានជាអតិប្បរមានៅឡើយ។

### ៥.១. បង្កើនភាពជាអ្នកដឹកនាំ, សមត្ថភាពគ្រប់គ្រងនិងបណ្តុះឆន្ទៈកែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ

គោលបំណងនេះ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន២ រួមមាន ៥១.១ ពង្រឹងភាពជាអ្នកដឹកនាំនិងសមត្ថភាពគ្រប់គ្រង និង ៥១.២ បង្កើនឆន្ទៈកំណែទម្រង់ភាពជាម្ចាស់ និងការទទួលខុសត្រូវ។ បើពិនិត្យលើលទ្ធផលសម្រេចបាន គោលបំណងនេះអនុវត្តបានតែ៥៦% ដោយក្នុងនោះ ចង្កោមសកម្មភាព ៥១.១ សម្រេចបាន ៦១% និង៥១.២ សម្រេចបានតែ ៥៣%។

ដោយផ្អែកលើវឌ្ឍនភាពធៀបនឹងសូចនាករមានសូចនាករចំនួន៣ សម្រេចបានពេញលេញតាមគោលដៅដែលបានកំណត់ ពោលគឺ ចក្ខុវិស័យបេសសកម្មរបស់ប្រធានការិយាល័យ អនុប្រធាននាយកដ្ឋាន និងប្រធាននាយក

ដ្ឋានត្រូវបានរៀបចំចងក្រង និងដាក់ឱ្យអនុវត្ត, បានពិនិត្យ និងផ្ទៀងផ្ទាត់លើគ្រប់ទិដ្ឋភាព (កម្រិតថ្នាក់ដឹកនាំជំនាញ) លើការរៀបចំចងក្រង និងផ្សព្វផ្សាយកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ហិរញ្ញវត្ថុសាធារណៈ ការគ្រប់គ្រងបុគ្គលិក កិច្ចដំណើរការស្ថាប័ន បច្ចុប្បន្នកម្មប្រចាំឆ្នាំនូវសទ្ទានុក្រមគតិយុត្តសម្រាប់កសហវ បច្ចុប្បន្នកម្មកម្រងសម្រង់បទប្បញ្ញត្តិច្បាប់សំខាន់ៗទាក់ទងសមត្ថកិច្ចកសហវ បច្ចុប្បន្នកម្មកម្រងសម្រង់បទប្បញ្ញត្តិច្បាប់សំខាន់ៗទាក់ទងនឹងពន្ធដារ និងស្តង់ដារវាសាធារណៈសម្រាប់កសហវ, និងសិក្សាស្រាវជ្រាវផែនការយុទ្ធសាស្ត្រគ្រប់គ្រងយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្ស និងបញ្ជីសារពើពន្ធទ្រព្យសម្បត្តិរដ្ឋនៃអគ្គនាយកដ្ឋានពន្ធដារត្រូវបានរៀបចំ។

ដោយឡែក សូចនាករចំនួន៥ ដែលមិនសម្រេចបានតាមគោលដៅរួមមាន ចក្ខុវិស័យ និងបេសសកម្មរបស់នាយកដ្ឋានត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត, សេចក្តីព្រាងសារាចរស្តីពីវិធាន និងនីតិវិធីនៃការបង្កើនសមត្ថភាពជាអ្នកដឹកនាំ និងសមត្ថភាពគ្រប់គ្រងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានរៀបចំ, ការផ្តល់ប្រឹក្សាច្បាប់ក្រៅផែនការដែលបានរៀបចំសម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព, ការរៀបចំចងក្រង និងផ្សព្វផ្សាយកម្រងសម្រង់បទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធនឹងគយនិងរដ្ឋាករ ឧស្សាហកម្មហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ គណនេយ្យ មគ្គុទេសន៍នីតិកម្មសម្រាប់កសហវ និងតាមកម្រងសម្រង់នីមួយៗ, និងការរៀបចំ សម្របសម្រួល និងស្វែងយល់ពីឧត្តមានុវត្តអន្តរជាតិក្នុងការផ្លាស់ប្តូរបទពិសោធអន្តរជាតិពាក់ព័ន្ធនឹងភាពជាអ្នកដឹកនាំក្នុងវិស័យសាធារណៈ និងការងារកែទម្រង់ជូនថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីរាជការ។

មូលហេតុគោលបំណងនេះសម្រេចបានតិច ដោយសារតែមានការងារអាទិភាពផ្សេងទៀត, ចំនួនមន្ត្រីទទួលបន្ទុកការងារមានចំនួនកំណត់ និងទំហំការងារមានវិសាលភាពលើសពីការគ្រោងទុក និងទាមទារឱ្យមានការសិក្សាបន្ថែមទៀត។

ចំណែកសកម្មភាព៥១.១.៣.រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្ស កសហវ រយៈពេល ០៣ ឆ្នាំ ២០១៧-២០១៩ នាយកដ្ឋានបុគ្គលិកស្នើសុំលើកសកម្មភាពត្រីមាសទី១ ទៅអនុវត្តនៅត្រីមាសទី២ ។

ដូចនេះ យើងអាចសន្និដ្ឋានបានថា គោលបំណងទី១ នេះ មិនទាន់បានអនុវត្តពេញលេញគ្រប់ជ្រុងជ្រោយសម្រាប់ត្រីមាសទី១ នេះនៅឡើយទេ។ម្យ៉ាងវិញទៀត អង្គភាពមួយចំនួនមិនបានរៀបចំសកម្មភាពគាំទ្រ ដើម្បីពង្រឹងដល់ភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងការបណ្តុះឆន្ទៈកំណែទម្រង់ ធ្វើឱ្យភាពជាម្ចាស់និងការទទួលខុសត្រូវនៅមានកម្រិតទាបនៅឡើយ ដែលនេះអាចបញ្ជាក់ឱ្យឃើញថា អង្គភាពមួយចំនួនពុំទាន់ឱ្យតម្លៃខ្ពស់ ឬក៏យល់ថា ខ្លួនត្រូវធ្វើអ្វីដើម្បីគាំទ្រដល់គោលបំណងនេះ។

**៥.២. បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត**

គោលបំណងនេះ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន២ រួមមាន ៥២.១. ពិនិត្យមើលឡើងវិញពីប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការបណ្តុះបណ្តាល និងរៀបចំផែនការកសាងសមត្ថភាពថ្មី និង ៥២.២. ពិនិត្យមើលឡើងវិញពីយន្តការ និងអភិក្រមនៃការផ្តល់ការលើកទឹកចិត្តរយៈពេលកន្លងមកនិងរៀបចំឱ្យមានយន្តការ និងអភិក្រមថ្មីស្តីពីការផ្តល់ការលើកទឹកចិត្តដែលមានសមធម៌ និងសង្គតិភាព។ ជារួម ផ្អែកលើសកម្មភាពសម្រេចបានគោលបំណងនេះសម្រេច បាន ៧៩%។

បើពិនិត្យលើលទ្ធផលសម្រេចបាន គោលបំណងនេះអនុវត្តបានតែ៧៩% ដោយក្នុងនោះ ចង្កោមសកម្មភាព ៥២.១ សម្រេចបាន ៥៨% និង៥២.២ សម្រេចបាន១០០%។

ក្នុងនោះ ឃើញថា សូចនាករចំនួន២ សម្រេចបានពេញលេញតាមគោលដៅដែលបានកំណត់ ពោលគឺបាន ចងក្រងឯកសារបណ្តុះបណ្តាលលើការអនុវត្តថវិកាកម្មវិធី (១) ការរៀបចំផែនការថវិកា (២) នីតិវិធីអនុវត្តថវិកាកម្មវិធី (៣) នីតិវិធីនិងវិធីសាស្ត្រអនុវត្តកិច្ចលទ្ធកម្មសាធារណៈ (៤) កិច្ចបញ្ជីការគណនេយ្យ (៥) នីតិវិធីសវនកម្មផ្ទៃក្នុង (៦) នីតិវិធីអធិការកិច្ចហិរញ្ញវត្ថុ, និងបទពិសោធនិងបញ្ហាប្រឈមនៃការអនុវត្តប្រកាសលេខ៦១៦ ត្រូវបានសិក្សាអំពីស្ថានភាពបច្ចុប្បន្ន និងផែនការចុះត្រួតពិនិត្យសមិទ្ធកម្មត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តសម្រាប់ឆ្នាំ២០១៦។

ដោយឡែក សូចនាករ១ ដែលសម្រេចមិនបាន គឺ តម្រូវការបណ្តុះបណ្តាលរបស់ក្រសួង ស្ថាប័នទូទាំងប្រទេស ត្រូវបានវាយតម្លៃ (Training Needs Assessment)។

ដូចនេះ យើងអាចសន្និដ្ឋានបានថា គោលបំណងទី២ នេះ ក៏ស្ថិតនៅក្នុងកម្រិតមួយមធ្យមពុំទាន់ឆ្លើយតបបានទាំងស្រុងតាមទិសដៅដែលបានដាក់ចេញ។ មូលហេតុសំខាន់ៗ គឺសកម្មភាពមួយមិនបានអនុវត្ត, សកម្មភាពខ្លះអនុវត្តបានតិច និងពុំសូវមានសកម្មភាពដាក់បញ្ចូលទេ។

### ៥.៣. ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៣

គោលបំណងនេះ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពចំនួន៤ រួមមាន ៥៣.១.រៀបចំស្ថាប័នដើម្បីឆ្លើយតបនឹងដំណាក់កាលទី៣ រួមមាន (១)ការបញ្ចប់វិភាគមុខងារនៅគ្រប់អគ្គនាយកដ្ឋាននៃ កសហវ និងនាយកដ្ឋាន (២) រៀបចំនិងអនុវត្តផែនការកែសម្រួលរចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋាននិងនាយកដ្ឋាននីមួយៗ (៣) រៀបចំនិងផ្សព្វផ្សាយឯកសារណែនាំស្តីពីប្រព័ន្ធគ្រប់គ្រងថ្មី (៤) រៀបចំគោលនយោបាយសម្រាប់យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានវិទ្យានៅកសហវ (៥) ការប្រើប្រាស់ជំនួយបច្ចេកទេសប្រកបដោយប្រសិទ្ធភាព និង (៦) កែលម្អការអនុវត្តការងារតាមរយៈការបង្កើតការប្រើប្រាស់បច្ចេកវិទ្យា, ៥៣.២.ការអភិវឌ្ឍធនធានមនុស្សសម្រាប់ដំណាក់កាលទី៣ ដែលរួមមានការបណ្តុះបណ្តាលជំនាញទាំងនៅក្នុងកសហវ និងក្រសួង ស្ថាប័ន, ៥៣.៣.រៀបចំនិងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនង និងសម្របសម្រួលសម្រាប់ដំណាក់កាលទី៣ (ពុំទាន់មានសកម្មភាពអនុវត្ត), និង ៥៣.៤.កំណត់តួនាទី និងការទទួលខុសត្រូវសម្រាប់កែលម្អកិច្ចសម្របសម្រួលរវាងស្ថាប័ន និងអង្គភាព ។ ជារួមផ្អែកលើសកម្មភាពសម្រេចបានគោលបំណងនេះសម្រេចបាន ៧៥%។

បើពិនិត្យលើលទ្ធផលសម្រេចបាន គោលបំណងនេះអនុវត្តបានតែ ៧៥% ដោយក្នុងនោះ ចង្កោមសកម្មភាព ៥៣.១ សម្រេចបាន ៦៩% ,៥៣.២ សម្រេចបានតែ ៨៨% និង៥៣.៤. ៥០%។

ក្នុងនោះ ឃើញថា សូចនាករចំនួន៦ សម្រេចបានពេញលេញតាមគោលដៅដែលបានកំណត់ ពោលគឺទីតាំងមជ្ឈមណ្ឌលទិន្នន័យនិងទីតាំងសម្រាប់ធ្វើការត្រួតពិនិត្យបណ្តាញចែកចាយ ត្រូវបានកំណត់រួចរាល់ និងរចនាសម្ព័ន្ធនិងប្លង់នៃការតភ្ជាប់បណ្តាញ ICT ត្រូវបានសិក្សារួចរាល់, អង្គភាពថវិកានៃកសហវ បានចូលរួមវិបស្សនាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកានៃ កសហវ ឆ្នាំ២០១៧-២០១៩ និងវិបស្សនាស្តីពីការបូកសរុបត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តថវិកាកម្មវិធីរបស់ កសហវ, បានផ្សព្វផ្សាយនិងបណ្តុះបណ្តាលក្រុមលទ្ធកម្ម ព្រមទាំងបានចូលរួមប

ណ្តុះបណ្តាលជាមួយអគ្គនាយកដ្ឋានថវិកាជូនក្រសួង ស្ថាប័ន រាជធានី ខេត្តមួយចំនួន, មន្ត្រីរតនាគាររាជធានីទាំង២៥ បានទទួលការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ប្រព័ន្ធ FMIS ហើយបាននឹងកំពុងសាកល្បងប្រើប្រាស់តាមអង្គភាព, បានបណ្តុះបណ្តាលរដ្ឋទេយ្យករ រដ្ឋទេយ្យកររង និងបណ្តុះបណ្តាលស្តីពីការអនុវត្តថវិកាកម្មវិធីជូនអង្គភាពថ្នាក់កណ្តាល និងមន្ទីរខេត្ត រាជធានី ក្រុង នៃកសហវ ២៥ ខេត្តក្រុង, និងព័ត៌មានទិន្នន័យមគ្គុទេសក៍សេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានីខេត្តត្រូវបានប្រមូល និងបូកសរុប។

ដោយឡែក សូចនាករចំនួន៤ ដែលសម្រេចមិនបានពេញលេញ គឺការវិភាគមុខងារនៅនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ, ការជូនដំណឹងទៅគ្រប់អង្គភាពនៃនាយកដ្ឋានរដ្ឋបាលនិងបុគ្គលិកពាក់ព័ន្ធនឹងការរៀបចំបណ្តុះបណ្តាលមន្ត្រី (ត្រូវផ្ញើឈ្មោះទៅនាយកដ្ឋានបុគ្គលិក), ការរៀបចំវគ្គបណ្តុះបណ្តាលខ្លីលើការប្រើប្រាស់កម្មវិធីគណនេយ្យ, និងបណ្តុះបណ្តាលស្តីពីអង្គភាពថវិកាជូនមន្ត្រីរាជការថ្នាក់ក្រោមជាតិ។

ចំណែកចង្កោមសកម្មភាព៥៣.៤.១.រៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាព ការអនុវត្តកម្មវិធីកែទម្រង់ប្រចាំខែ ត្រីមាស និងឆ្នាំ មិនបានដាក់វឌ្ឍនភាពនោះទេ។

នៅក្នុងសកម្មភាព ៥៣.១.២. រៀបចំសារាចរស្តីពីការពិព័ណ៌នាលក្ខណៈសម្បត្តិរបស់មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ (នាយកដ្ឋានបុគ្គលិក), ៥៣.២.១. ការរៀបចំការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ផែនការយុទ្ធសាស្ត្រថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ), និង ៥៣.២.២.ការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តថវិកាកម្មវិធី ការរៀបចំ និងអនុវត្តថវិកា, គណនេយ្យសាធារណៈ និងកិច្ចបញ្ជីការគណនេយ្យ, លទ្ធកម្មសាធារណៈ, សវនកម្ម និងអធិការកិច្ចជូនដល់មន្ត្រីរាជការរបស់មន្ទីរ និងអង្គភាពជំនាញនៃរាជធានី ខេត្ត និងក្រសួង ស្ថាប័ន (វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ) បានស្នើលើកពេលអនុវត្តនៅត្រីមាសទី២ វិញ។

នៅក្នុងគោលបំណងនេះ បញ្ហាប្រឈមនៅត្រង់ថា មន្ត្រីនៅតាមរតនាគារខេត្ត២៥ រាជធានីខេត្តនៅមានកម្រិតយល់ដឹងពាក់ព័ន្ធ FMIS ដែលមានទាមទារឱ្យមានការបណ្តុះបណ្តាលបន្ថែម និងការជំរុញសកម្មភាពការងារនេះឱ្យបានខ្លាំងក្លាបន្ថែមទៀត ខ្វះមន្ត្រីទទួលបន្ទុកការងារ Update ទិន្នន័យចូលទៅក្នុងប្រព័ន្ធ E-doc និងមិនមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តការងារនេះឱ្យបានទាន់ពេល។

ដូចនេះ យើងអាចសន្និដ្ឋានបានថា គោលបំណងទី៣ នេះ ក៏ស្ថិតនៅក្នុងកម្រិតមួយមធ្យមពុំទាន់ឆ្លើយតបបានទាំងស្រុងតាមទិសដៅដែលបានដាក់ចេញ។

ជារួម សម្រាប់ផ្នែកនេះ យើងអាចសន្និដ្ឋានបានថា ទោះបីជាសកម្មភាពជាច្រើនបានអនុវត្តពេញលេញក្តី និងមិនពេញលេញក្តីក៏ពិតមែន តែបើពិនិត្យឱ្យបានល្អិតល្អន់ឃើញថា សកម្មភាពដែលបានដាក់ចេញហាក់ពុំទាន់មានទម្ងន់គ្រប់គ្រាន់ សម្រាប់បម្រើឱ្យផលប្រយោជន៍ពិតនៃផ្នែកនេះនៅឡើយទេ។ ដូចនេះ គ្រប់អគ្គនាយកដ្ឋានទាំងអស់ត្រូវការពង្រឹង និងបង្កើនសកម្មភាពជាក់លាក់និងមុតស្រួចបន្ថែមទៀត ដើម្បីធានាថា ការគាំទ្រដល់ការអនុវត្តកម្មវិធីប្រកបដោយជោគជ័យ និងចីរភាពអាចសម្រេចបានពិតប្រាកដ ជាពិសេស សម្រាប់ដំណាក់កាលទី៣ អគ្គនាយកដ្ឋានដែលពុំបានរៀបចំនិងពង្រឹងសកម្មភាពកែទម្រង់របស់ខ្លួន ត្រូវខិតខំព្យាយាមរៀបចំសកម្មភាពដែលបានដាក់ចេញ

ដើម្បីឱ្យគ្រប់អគ្គនាយកដ្ឋានទាំងអស់ក្លាយជាកម្លាំងចលករព្រមគ្នា ដើម្បីចូលរួមលើកស្ទួយការអនុវត្តកម្មវិធីកែទម្រង់បានទៅដោយរលូន៕

III. **បញ្ហាប្រឈម**

- ❖ ការកំណត់សូចនាកររបស់អគ្គនាយកដ្ឋាន/អង្គភាពនៃកសហវមិនទាន់មានភាពច្បាស់លាស់នៅឡើយ
- ❖ ខ្វះសកម្មភាពលម្អិតគាំទ្រដល់ចង្កោមសកម្មភាពមួយចំនួន÷
  - ៣៣.២.កំណត់ឱ្យបានច្បាស់នូវបន្ទាត់គណនេយ្យភាពក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈដើម្បីធានាសង្គតិភាពក្នុងថវិកាប្រចាំឆ្នាំ (កំណត់ពីការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួង-ស្ថាប័ននីមួយៗ រួមមាន ក្រសួងផែនការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានិងកសហវ
  - ៣៥.៥. ពង្រីកនិងពង្រឹង ការធ្វើសវនកម្មផ្ទៃក្រៅ
  - ៤៣.២.ពិគ្រោះយោបល់លើគោលការណ៍សវនកម្ម ផ្អែកលើសមិទ្ធកម្ម (អគ្គលេខាធិការដ្ឋាន កសហវ, អគ្គ.សវនកម្មផ្ទៃក្នុង?)
  - ៥៣.៣.រៀបចំនិងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនងនិងសម្របសម្រួលសម្រាប់ដំណាក់កាលទី៣
- ❖ សកម្មភាពលម្អិតមួយចំនួនមិនបានឆ្លើយតបទៅនឹងចង្កោមសកម្មភាព (៣២.១ និង៣២.២)
- ❖ អគ្គនាយកដ្ឋាន/អង្គភាពមួយចំនួននៅតែផ្ញើរបាយការណ៍វឌ្ឍនភាពមក អ.គ.ហ យឺត
- ❖ ថវិកាប្រចាំឆ្នាំ២០១៦ មិនទាន់អាចប្រើប្រាស់បាន ដោយរង់ចាំការអនុម័តពី EU
- ❖ ថវិកាទ្រទ្រង់គម្រោង FMIS នៅមិនទាន់មានភាពច្បាស់លាស់ ដែលអាចជាឧបសគ្គដល់ការអនុវត្តគម្រោង FMIS ទៅដំណាក់កាលទី២ បន្តទៀត
- ❖ រចនាសម្ព័ន្ធគ្រប់គ្រងប្រព័ន្ធ FMIS មិនទាន់ត្រូវបានរៀបចំពេញលេញ
- ❖ ការរៀបចំថវិកាលម្អិតរបស់ឃុំ-សង្កាត់ មានភាពយឺតយ៉ាវសម្រាប់ការយកមកបញ្ចូលក្នុងប្រព័ន្ធ FMIS ដែលធ្វើឱ្យការអនុវត្តថវិកាតាមប្រព័ន្ធ FMIS មានភាពយឺតយ៉ាវ។
- ❖ គោលការណ៍ណែនាំ ស្តីអំពីការអនុវត្តថវិកាកម្មវិធីមិនទាន់បានផ្សាភ្ជាប់ពេញលេញជាមួយនឹងការអនុវត្តថវិកាកម្មវិធីនៅក្នុងប្រព័ន្ធ FMIS
- ❖ មានសេចក្តីត្រូវការចាំបាច់ជាក់ស្តែងក្នុងការលើកកម្ពស់សមត្ថភាពនៃភាពជាអ្នកដឹកនាំក្នុងការសម្រសម្រួលលើការងារបច្ចេកទេស FMIS

IV. **សំណូមពរ**

- ❖ អគ្គនាយកដ្ឋាន/អង្គភាពនៃកសហវ គួរពិនិត្យមើលឡើងវិញពីសូចនាករដែលបានកំណត់រួច និង សូចនាករដែលដៃគូអភិវឌ្ឍន៍បានស្នើ ដើម្បីត្រៀមរៀបចំផែនការសកម្មភាពអនុវត្ត ២០១៧
- ❖ លើកកម្ពស់តួនាទីរបស់វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានកិច្ចសហការជាមួយអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធក្នុងការរៀបចំយុទ្ធសាស្ត្រ ស្តីពីការអភិវឌ្ឍន៍សមត្ថភាពការងារហិរញ្ញវត្ថុសាធារណៈជូនដល់ស្ថាប័ននីតិប្បញ្ញត្តិ, ស្ថាប័ននីតិប្រតិបត្តិ, ស្ថាប័នតុលាការ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ល។
- ❖ សកម្មភាពដែលត្រូវបានស្នើទៅអនុវត្តនៅត្រីមាសបន្ទាប់

- ៣៦.៦.៧. ផ្តល់មតិប្រឹក្សាច្បាប់លើលិខិតបទដ្ឋានគតិយុត្តសម្រាប់រៀបចំនីតិវិធី និងគោលការណ៍សម្រាប់អនុវត្តថវិកា កម្មវិធីពេញលេញ និងអង្គភាពថវិកា សម្រាប់ថវិកាថ្នាក់ក្រោមជាតិ (នាយកដ្ឋាននីតិកម្ម)
- ៥១.១.៣. រៀបចំយុទ្ធសាស្រ្តគ្រប់គ្រងនិងអភិវឌ្ឍន៍ធនធានមនុស្ស កសហវ រយៈពេល០៣ ឆ្នាំ ២០១៧-២០១៩ (នាយកដ្ឋានបុគ្គលិក)
- ៥៣.១.២. រៀបចំសារាចរស្តីពីការពិព័ណ៌នាលក្ខណៈសម្បត្តិរបស់មន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានបុគ្គលិក)
- ៥៣.២.១. ការរៀបចំការបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ផែនការយុទ្ធសាស្រ្តថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (អគ្គ.ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ)
- ៥៣.២.២. ការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តថវិកាកម្មវិធី ការរៀបចំ និងអនុវត្តថវិកា, គណនេយ្យសាធារណៈ និងកិច្ចបញ្ជីការគណនេយ្យ, លទ្ធកម្មសាធារណៈ, សវនកម្ម និងអធិការកិច្ចជូនដល់មន្ត្រីរាជការរបស់មន្ទីរ និងអង្គភាពជំនាញនៃរាជធានី ខេត្ត និងក្រសួង ស្ថាប័ន។ (វិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)

V. **សេចក្តីសន្និដ្ឋាន**

របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី១ ឆ្នាំ២០១៦ ទោះបីមានវឌ្ឍនភាពស្របទៅតាមសូចនាករ ដែលបានកំណត់ក៏ដោយ ក៏នៅមានសូចនាករមួយចំនួនទៀតនៅមិនទាន់សម្រេចបានតាមគោល ដៅនៅឡើយ ដោយសារកត្តាអត្តនោម័ត/ សត្យានុម័ត។ របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសទី១ នេះ ក៏បានរំលេចឱ្យឃើញពីភាពចាំបាច់ក្នុងការពិនិត្យមើលឡើងវិញ និងកែសម្រួលសូចនាករ/ សកម្មភាពលម្អិតមួយចំនួន (នៅត្រីមាសទី៣) ដើម្បីសម្រេចបានតាមគោលដៅរួមនៃ CAP3។